01382126

E1/468.1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

# <u>កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី</u>

# <u>ជំនុំជម្រះក្តីនៅដំណាក់កាលពីរ</u>

## <u>សាធារណៈ</u>

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៦**

**ម៉ោង ០៩:០១នាទី**

**សវនាការលើកទី៤៤៩**

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 19-Jan-2017, 13:18
CMS/CFO: Sann Rada

**ចៅក្រមសាលាដំបូង៖**

ចៅក្រម យ៉ា សុខន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក រ៉ូជ័រ ហ្វីលីព *(Mr.Roger PHILLIP)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

កញ្ញា សុង ឆវ័ន្ត

លោក វីល្លៀម ស្មីត *(Mr.William Smith)*

លោក ឌេល លីសាក់ *(Mr. Dale Lysak)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោកស្រី ដូរីន ជិន *(Mrs. Doreen CHEN)*

លោក លីវ សុវណ្ណា

លោក វិចទ័រ កូប៉េ *(Mr. Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍ *(Ms.Marie GUIRAUD)*

លោក ឡៅ ជុនធី

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោកស្រី ស្វ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | ភាសា |
|---|---|
| ចៅក្រម យ៉ា សុខន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក ខេល លីសាក់ | អង់គ្លេស |
| លោក វីល្លៀម ស្មីត | អង់គ្លេស |
| លោក រ៉ិចឌ័រ កូប៉េ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោកស្រី ដូរីន ជិន | អង់គ្លេស |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក ឡោ ជុនធី | ខ្មែរ |
| លោកស្រី ផាន់ ហ៊ីម (2-TCW-914) | ខ្មែរ |

# ខ្លឹមសារ

**ការសួរសំណួរទៅសាក្សី: លោកស្រី ផាន់ ហ៊ឹម/ ផាន់ ហ៊ឹម ហៅ ធី** (2-TCW-914)

សួរដោយលោក ហ្សង់ម៉ាក ឡាវែន៍ ផ្តើមពី................................................................ ទំព័រ ៣

សួរដោយលោកស្រី ដូរីន ជិន ផ្តើមពី ...................................................................... ទំព័រ ៦

សួរដោយកញ្ញា អង់តា ហ្គិសសេ ផ្តើមពី................................................................... ទំព័រ ១៥

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០០:៤៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះនឹងបន្តស្តាប់សក្ខីកម្មសាក្សី ផាន់ ហ៊ឹម បញ្ចប់។ បន្ទាប់ពីបញ្ចប់ការស្តាប់សក្ខីកម្មសាក្សី ផាន់ ហ៊ឹម អង្គជំនុំជម្រះនឹងស្តាប់សារណារផ្ទាល់មាត់របស់ភាគីពាក់ព័ន្ធទៅនឹងការកោះហៅបុគ្គលដែលមានរហស្សនាម 2-TCE-93។

ក្រឡាបញ្ជីសវនាការ លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលទាំងឡាយដែលអង្គជំនុំជម្រះកោះអញ្ជើញឱ្យចូលរួមក្នុងកិច្ចដំណើរការសវនាការនៅថ្ងៃនេះ។ សូមអញ្ជើញ!

[០៩:០១:៣៩]

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះ មានវត្តមាន លើកលែងតែលោក គង់ សំអុន មេធាវីជាតិការពារក្តីឱ្យលោក ខៀវ សំផន អវត្តមានដោយមូលហេតុផ្ទាល់ខ្លួន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការនៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ ហើយសាក្សីដែលត្រូវមកផ្តល់សក្ខីកម្មបញ្ចប់នៅថ្ងៃនេះ គឺលោកស្រី ផាន់ ហ៊ឹម លោកស្រីមានវត្តមានរួចហើយនៅក្នុងបន្ទប់សវនាការនេះ។ ហើយនៅថ្ងៃនេះ មិនមានសាក្សីបម្រុងនោះទេ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រី សែ កុលវុឌ្ឍី។

ជាដំបូងអង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះ របស់ជន

ជាប់ចោទ នួន ជា ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៦ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួមនិងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការនៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៦។

[០៩:០២:៥៤]

មេធាវីការពារក្តីរបស់ខ្លួនបានប្រាប់អំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះ មិនអាចបកស្រាយថា ជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្តីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់ទៅនឹងភស្តុតាងក្នុងការដាក់បង្ហាញ ឬដាក់ជូនតុលាការនេះ គ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យព្យាបាល ថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៦ បានកត់សម្គាល់ថា ស្ថានភាពសុខភាពរបស់លោក នួន ជា ថ្ងៃនេះមានអាការៈ ឈឺចង្កេះជាប្រចាំ អង្គុយយូរកាន់តែឈឺ និងបានផ្តល់អនុសាសន៍ថា សូមឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។

ផ្អែកលើមូលដ្ឋាននេះ និង យោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះ យល់ព្រមនិងអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួមនិងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅខាងក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួមនិងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅខាងក្រោមសាលសវនាការនេះ ក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:០៣:១១]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក មានសំណួរចំពោះសាក្សីរូបនេះ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** ជម្រាបសួរលោកស្រីសាក្សី។ លោកស្រីសាក្សី ខ្ញុំមានសំណួរមួយចំនួន ដើម្បីសួរបន្តទៅកាន់លោកស្រី។ កាលពីម្សិលមិញលោកស្រីបានផ្តល់សក្ខីកម្មថា ក្នុងក្របខ័ណ្ឌនៃមុខងាររបស់លោកស្រីនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ លោកស្រីទទួលបន្ទុកក្មេងៗ។ ហើយពីរដង<ក្នុងពេលខុសគ្នា> គេប្រគល់ក្មេងទាំងអស់ហ្នឹងឲ្យជូនលោកស្រី ពេលដែលលោកស្រីធ្វើការឲ្យក្រសួងពាណិជ្ជកម្ម។ តើខ្ញុំយល់អ៊ីចឹងត្រឹមត្រូវទេ លោកស្រីពិតជាបានឆ្លើយអ៊ីចឹងទេ កាលពីម្សិលមិញនោះ?

**លោកស្រី ផាន់ ហ៊ីម៖**

**ឆ៖** ចាស ពិតជាត្រឹមត្រូវ ព្រោះទី១ ខ្ញុំនៅឯសហករណ៍។ ដល់ពេលមកក្រោយនេះ ខ្ញុំមកនៅក្រសួងពាណិជ្ជកម្មនេះ គេប្រគល់ឲ្យទៅបង្រៀនកុមារ។ ត្រឹមត្រូវហើយលោកអាជ្ញា។

**ស៖** តើកុមារដែលគេប្រគល់ជូនលោកស្រីឲ្យបង្រៀនហ្នឹង មានអាយុប៉ុន្មានដែរ?

**ឆ៖** កុមារដែលខ្ញុំបង្រៀននៅក្រសួងពាណិជ្ជកម្ម ចាប់ពីអាយុ៧ឆ្នាំឡើងមក រហូតដល់អាយុ១២ឆ្នាំ។

**ស៖** តើលោកស្រីបង្រៀនអ្វីខ្លះដល់កុមារទាំងអស់នុ៎ង លោកស្រីបង្រៀនពួកគេឲ្យចេះអាន ចេះសរសេរ?

**ឆ៖** ខ្ញុំចាប់ផ្តើមបង្រៀនដំបូង បង្រៀនពីស្រះ "អ" ស្រះ "ា" ដល់ចេះហើយ បង្រៀន "ក" "ខ"។ បង្រៀន "ក" "ខ"ចេះហើយ បានមកបំបែកជាអក្សរប្រកបជាផ្ញើជើង ហើយបង្រៀនជាលេខបូក លេខដក លេខគុណ លេខចែក តាមតម្រេះដែលខ្ញុំរៀនបានបន្តិចបន្តួច។

[០៩:០៧:១៨]

**ស៖** ពេលដែលគេឲ្យលោកស្រីបង្រៀនក្មេងៗទាំងអស់ហ្នឹង គេមានឲ្យលោកស្រីបង្រៀនពីរឿងនយោបាយទេ? មានផ្នែកណាមួយនៃមេរៀនរបស់លោកស្រីហ្នឹង គឺមានការបំពាក់បំប៉ននយោបាយទៅដល់កុមារទាំងអស់ហ្នឹងទេ?

**ឆ៖** អត់មានទេ មានតែឲ្យបង្រៀនជាអក្សរសាស្ត្រខ្មែរយើងហ្នឹងទេ អត់មានបំពាក់បំប៉នផ្នែក

01382133



E1/468.1

នយោបាយអីទេ។

**ស៖** គេអត់មាន<សុំ>ឲ្យលោកស្រី<ពន្យល់អំពីតួនាទីរបស់>អង្គការ ឬក៏គ្រួសារ<ទេឬ? ឧទាហរណ៍ដូចថា> តើ<អ្វីជាភាព>ស្មោះត្រង់<ហើយតើត្រូវស្មោះត្រង់ជាមួយអ្នកណា>?

**ឆ៖** គេអត់ឲ្យបង្រៀនខាងនេះទេ ប៉ុន្តែគេគ្រាន់តែប្រាប់យើងជាអ្នកបង្រៀនហ្នឹង គ្រាន់តែប្រាប់កុមារហ្នឹងថា ចូលរៀនហ្នឹងឲ្យគោរពអង្គការវិន័យទៀងទាត់ពេលវេលា។ តែប៉ុណ្ណឹងទេ។

[០៩:០៨:៥៣]

**ស៖** គេមានបានណែនាំឲ្យលោកស្រីថា ត្រូវពន្យល់ប្រាប់កុមារទាំងអស់នុ៎ងថា ត្រូវតែគោរពអង្គការ ឬក៏គោរពឪពុកម្ដាយរបស់ខ្លួន?

**ឆ៖** ប្រាប់ឲ្យគោរពអង្គការ ព្រោះមកនៅក្នុងជួរបក្សហើយ គេឲ្យយើងគោរពក្នុងអង្គការវិន័យ ឲ្យមករៀនសូត្រហ្នឹង ឲ្យទៀងទាត់ពេល ឲ្យស្ដាប់បង្គាប់ដែលគ្រូបង្ហាត់។

**ស៖** ចុះតួនាទីឪពុកម្ដាយនោះ អង្គការទទួលស្គាល់ថា ឪពុកម្ដាយហ្នឹងមានតួនាទីអ្វីចំពោះកូនៗរបស់ខ្លួនទេ ឬក៏អង្គការហ្នឹងគេណែនាំថា លែងមានឪពុកម្ដាយទៀតហើយ គឺអង្គការហ្នឹងហើយជាឪពុកម្ដាយនោះ?

**ឆ៖** កាលដែលខ្ញុំនៅបង្រៀនកុមារហ្នឹង អត់ដែលឃើញមានឪពុកម្ដាយមកទេ។ តែគ្រាន់តែប្រាប់ថា យើងនៅក្នុងជួរបដិវត្តន៍នេះ យើងត្រូវតែគោរពអង្គការវិន័យ។ អង្គការហ្នឹងហើយដែលជាឪពុកម្ដាយ។

**ស៖** ដូច្នេះមានន័យថា អង្គការគឺជាឪពុកម្ដាយ។ ហើយបើឪពុកម្ដាយបង្កើតហ្នឹងគឺថាលែងមានទៀតហើយ។ លោកស្រីមិនដែលឃើញទេ មែនទេ?

**ឆ៖** អត់ដែលឃើញទេ លោកប្រធាន។

[០៩:១១:០០]

**ស៖** តើលោកស្រីមានបង្រៀនចម្រៀងទៅកុមារទាំងអស់ហ្នឹងទេ? ហើយចម្រៀងទាំងអស់ហ្នឹងគឺជាចម្រៀងដែលរៀនសូត្រអំពីគោលការណ៍បដិវត្តន៍មែនទេ?

**ឆ៖** ខ្ញុំអត់ដែលបានបង្រៀនជាចម្រៀងផង ព្រោះរូបខ្ញុំក៏អត់ចេះចម្រៀងដែរ។

**ស៖** តើគេមានបានណែនាំប្រាប់លោកស្រីត្រូវបង្រៀនកុមារឲ្យប្រុងប្រយ័ត្នចំពោះខ្មាំង? លោកស្រីមានបានបង្រៀនអំពីបញ្ហាខ្មាំងទៅកាន់កុមារទាំងអស់ហ្នឹងទេ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** គេប្រាប់ដែរ ប្រាប់ឲ្យបង្រៀនថា ឲ្យយើងហ្នឹងប្រុងប្រយ័ត្នខ្លាំង ដូចជាយើងនៅតាមក្រសួងមន្ទីរអ៊ីចឹង ច្រើនតែមានគិញ ចារកម្មអីចូលបន្លំបោកគ្រាប់បែកចូលធ្វើជា សេ.អី.អា ទៅជា ធ្វើដូចគោ ដូចខ្លាអ៊ីចឹង ព្រោះខ្ញុំនៅឯសហករណ៍ហ្នឹង ច្រើនមានព្រៃ នៅក្នុងព្រៃ នៅក្នុងកន្លែងមន្ទីរសេះសហ្នឹងសុទ្ធតែព្រៃធំ ដើមឈើធំៗ។ ម្ល៉ោះហើយគេប្រាប់អ៊ីចឹងថា ឲ្យការពារ ឲ្យកុមារហ្នឹង ជួយការពារជួយប្រុងប្រយ័ត្នតាមដានខ្លាំង។

[០៩:១២:៣៧]

**ស៖** ចុះគេមានណែនាំឲ្យលោកស្រីបង្រៀនកុមារថា វៀតណាមជាខ្មាំងទេ?

**ឆ៖** អត់មានទេ។ អត់ -- កាលហ្នឹងអត់មានឮឈ្មោះ និយាយពីរឿងវៀតណាមយួនអីទេ។

**ស៖** ខ្ញុំមានសំណួរមួយចំនួនទៀតដែលត្រូវសួរលោកស្រី។ ពេលដែលលោកស្រីធ្វើការនៅក្រសួងពាណិជ្ជកម្ម តើលោកស្រីធ្លាប់ទាក់ទងជាមួយនឹងជនបរទេសទេ ឧទាហរណ៍ដូចជាភ្ញៀវដែលមកទស្សនកិច្ចនៅកម្ពុជា ឬក៏ភ្ញៀវមកទិញទំនិញ ឬក៏អ្នកការទូតបរទេស? លោកស្រី និយាយរួម តើលោកស្រីធ្លាប់ឃើញជនបរទេសទេ?

**ឆ៖** ជនបរទេស ខ្ញុំធ្លាប់ឃើញតែជិះតាមឡាន តែចូលក្នុងក្រសួងពួកខ្ញុំពាណិជ្ជកម្មចែកចាយនេះអត់ដែលឃើញមានជនបរទេសទេ។

**ស៖** ពេលដែលលោកស្រីធ្វើការនៅក្បែរវត្តទួលទំពូង លោកស្រីដឹងថានៅជុំវិញនុ៎ងមានស្ថានទូតទេ?

**ឆ៖** អត់ដឹងផង នៅកន្លែងនុ៎ង ដឹងតែពីនៅក្នុងនេះហ្នឹង។ និយាយរួមទៅគេមិនឲ្យយើងចេញក្រៅទៅខាងណាផង ពេលចេញទៅធ្វើការ ចូលក្នុងឃ្លាំងទៅនាំគ្នាអង្គុយសម្រិតសម្រាំងក្នុងឃ្លាំងហ្នឹងទៅ។ ពេលដល់ម៉ោង ក៏នាំគ្នាចេញមកកន្លែងវិញមក ហូបបាយហូបអី ចូលផ្ទះទៅ អត់មានដែលដឹងស្ថានទូតហ្នឹងនៅកន្លែងណាទេ។

[០៩:១៤:៥៣]

**ស៖** លោកស្រីមិនដែលឮគេនិយាយថានៅជិតវត្តទួលទំពូងមានស្ថានទូត ដូចជាស្ថានទូតចិនអីជាដើមហ្នឹង លោកស្រីមិនដែលឮទេមែនទេ?

**ឆ៖** ចាស ខ្ញុំអត់ដែលឮផង។

**ស៖** ចុះលោកស្រីធ្លាប់ឮគេនិយាយអំពីមន្ទីរស-២១ទេ?

**ឆ៖** ធ្លាប់ឮដែរ ប៉ុន្តែមិនដឹងនៅកន្លែងណា។

**ស៖** លោកស្រីឮអ្វីខ្លះពីស-២១?

**ឆ៖** ចាស គ្រាន់តែគេថាកន្លែងមន្ទីរស-២១ ប៉ុន្តែមិនដឹងថាកន្លែងស-២១ហ្នឹង គេធ្វើខាងអី គេតួនាទីអី ក៏ខ្ញុំអត់ដឹងដែរ។

**ស៖** សូមអរគុណលោកស្រីសាក្សី។ លោកប្រធានខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីដើមបណ្តឹងរដ្ឋប្បវេណី លោកមានសំណួរទៀតទេ?

**លោក ឡោ ជុនធី៖**

អត់មានសំណួរទេ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។ សូមអញ្ជើញលោកមេធាវីការពារក្តីលោក នួន ជា។

[០៩:១៦:៤៣]

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោកស្រី ដូរីន ជិន៖**

ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម។ លោកស្រីសាក្សី ខ្ញុំមានសំណួរមួយចំនួនសួរទៅលោកស្រីនៅព្រឹកនេះ។

**ស៖** សំណួរខ្ញុំដំបូងគឺនិយាយអំពីបទពិសោធន៍របស់លោកស្រីភ្លាមៗ<ក្រោយរំដោះ>ទីក្រុងភ្នំពេញ។ នៅពេលឆ្លើយទៅនឹងសំណួររបស់សហព្រះរាជអាជ្ញា លោកស្រីឆ្លើយថា <នៅឆ្នាំ១៩៧៥> លោកស្រីត្រូវបានគេបញ្ជូនទៅឲ្យបោសសម្អាតផ្សារថ្មីក្រោយជ័យជម្នះនោះ ហើយ<ក្រោយពីលោកស្រីបានសម្អាតទីតាំងនោះ និង>ប្រមូលយកនូវជយភណ្ឌទាំងអស់ <លោកស្រីត្រូវបានគេចាត់តាំងឲ្យមើលឃ្លាំង ដើម្បីផ្គត់ផ្គង់អាហារដល់កម្មករ>។ សំណួររបស់ខ្ញុំទាក់ទងទៅនឹងអ្វីដែលលោកស្រីនិយាយអំពីការប្រមូលនូវរបស់ជយភណ្ឌ។ តើលោកស្រីអាចរៀបរាប់បានទេ តើលោកស្រីប្រមូលរបស់អ្វីខ្លះដែលជារបស់ជយភណ្ឌនោះ?

**លោកស្រី ផាន់ ហ៊ីម៖**

**ឆ៖** ប្រមូលជាជយភណ្ឌដែលសម្អាតនៅក្នុងទីផ្សារថ្មីហ្នឹងច្រើនណាស់ មានតាំងពីជ្រុញចិញ្ច្រាំ

សាច់ជ្រូក មានតាំងពីចង់ថាគ្រប់មុខទាំងអស់ណ៎ា ក្នុងអាដែងរបស់របរដែលខ្មែរយើងប្រកបអាជីវកម្ម នៅក្នុងហ្នឹង ថាប្រមូលទាំងអស់ យកឲ្យស្អាតពីទីផ្សារហ្នឹង ហើយលាងបោសសម្អាតឲ្យស្អាត តាំងចាប់ផ្ដើមរៀបរយចែកចាយកម្មករហ្នឹង។ ជយភណ្ឌអស់ហ្នឹង គ្រាន់ប្រមូលទម្រាំតែអស់ជិតប្រហែលជិតមួយខែ យកទៅចោលនៅស្ទឹងមានជ័យ យកទៅចោលនៅព្រែកព្នៅ សុទ្ធតែជ្រុញចិញ្ច្រាំសាច់ជ្រូក ជ្រុញកាប់សាច់គោ កាប់អីហ្នឹង ជ្រុញធំៗហ្នឹង។ មានតែប៉ុណ្ណឹងទេចាស។

[០៩:១៨:១៥]

**ស៖** ចូលទៅនឹងសំណួរបន្ទាប់នេះ និយាយអំពីព្រឹត្តិការណ៍ដែលលោកស្រីបានលើកឡើងសង្ខេបទេកាលពីម្សិលមិញ។ នៅពេលដែលលោកស្រីនិយាយអំពីគេចាត់តាំងឲ្យលោកស្រីទៅបង្រៀនក្មេងៗម្សិលមិញនៅម៉ោង<១៤:០៧> ពេលឆ្លើយទៅសហព្រះរាជអាជ្ញា លោកស្រីបានឆ្លើយថាលោកស្រីត្រូវបានគេបញ្ជូនទៅឲ្យបង្រៀនក្មេងៗ<នៅឫស្សីកែវ។> ស្ថានភាពនៅពេលនោះគឺថាស្មៀមស្ងាត់ណាស់មានកងទ័ពមកពីជ្រោយចង្វាដែលចូលមកពេលយប់ មកលួចអង្ករនៅក្នុងឃ្លាំងអង្ករ។ មានថ្ងៃមួយគេបានចូលមកកន្លែងដែលលោកស្រីសម្រាក គេយកក្រមា ស្បែកជើងរបស់លោកស្រីដោយសារវាស្វាត់ពេក អីចឹងអង្គការ ក៏ចាត់តាំងឲ្យលោកស្រីទៅបង្រៀនក្មេងៗនៅទួលទំពូង។ លោកស្រីបានលើកឡើងថា កងទ័ពបានមកលួចរបស់របររបស់លោកស្រី<គឺមកពីស្ពានជ្រោយចង្វា>។ តើធ្វើម៉េចបានជាលោកស្រីដឹងថាកងទ័ពនោះមកពីណា?

**ឆ៖** បានជាដឹង ព្រោះពួកអ្នកខ្ញុំនៅក្នុងមន្ទីរហ្នឹង ចាសបានស្គាល់ដេញទៅ ឃើញរត់ទៅម្ដុំត្រង់ហ្នឹង ម្ដុំកន្លែងយោធា កន្លែងស្ដាតចាស់ហ្នឹង ចុងគល់ស្ពានហ្នឹង ឃើញវារត់ទៅម្ដុំត្រង់ហ្នឹងចូលកន្លែងហ្នឹងបាត់ទៅ។

**ស៖** ដូច្នេះលោកស្រី<បានស្គាល់ពួក>គេ គឺតើពួកគេពិតជាបានមកលួចរបស់របរលោកស្រីមែនទេ ឬក៏គ្រាន់ថាប៉ុនប៉ង ហើយវាអត់បានលួចរបស់របរនោះទេ?

[០៩:១៩:៤៧]

**ឆ៖** បានលួច បានចូលទៅក្នុងចង្ក្រានបាយហ្នឹង លួចយកបាយ យកម្ហូបម្ហាដែលសល់នៅក្នុងដែលយើងបរិភោគហូបរួចហើយ យើងទុកដាក់ក្នុងចង្ក្រានបាយហ្នឹងចាក់សោរហើយ នៅតែគាស់ទ្វារបង្អួចខាងក្រោយចូលយក។ ហើយពួកខ្ញុំដែលពេលងូតទឹកអីចឹង បោកក្រមាៗទទឹកអីចឹង យកហាលនឹងគ្រែក្បាលដេកហ្នឹង ដល់ពេលដេកលក់ទៅវាចូលយក ហើយកំសៀវទឹកដាក់នៅក្នុងហ្នឹងក៏វាឃ្លរយក

ទៅបាត់ ទាំងក្រមា ទាំងស្បែកជើង ទាំងកំសៀវទឹក។ ដល់ប៉ុណ្ណឹង ពេលហ្នឹងទៅបានចាប់អារម្មណ៍ថា ពួកហ្នឹងចូលយកសព្វគ្រប់ហ្នឹងទៅបានរាយការណ៍ទៅប្រាប់ថ្នាក់លើទៅ បានថ្នាក់លើដកឲ្យទៅនៅទួលទំពូងទៅ។

**ស៖** តើលោកស្រីមានធ្លាប់បានឮព្រឹត្តិការណ៍បែបនេះដែរទេ នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ដែលប្រជាជនហ្នឹង<>ត្រូវបានគេលួចរបស់របររបស់គាត់ ដូចលោកស្រីដែរ<>? មានឮដែរ?

**ឆ៖** អត់មានឮផង ព្រោះក្រសួងខ្ញុំនៅតែក្រសួង កន្លែងក្រសួងរបស់ខ្ញុំហ្នឹង កន្លែងគេផ្សេង ខ្ញុំអត់ដែលឮផង។

**ស៖** ហើយសំណួរចុងក្រោយពាក់ព័ន្ធប្រធានបទនេះ តើលោកស្រីមានដឹងទេ តើអង្គភាពកងទ័ពមួយណាដែលឈរជើងនៅក្បែរស្ពានជ្រោយចង្វា?

**ឆ៖** ខ្ញុំអត់ដឹងផង ដឹងកងពលខាងណាផង។

[០៩:២១:៣៩]

**ស៖** ឥឡូវ ខ្ញុំចូលទៅនិយាយអំពីការរៀបការរបស់លោកស្រី។ ម្សិលមិញនេះ នៅពេលដែលលោកស្រីនិយាយអំពីកាលៈទេសៈនៃពេលរៀបការរបស់លោកស្រីៗ បានលើកឡើងពីរបីដងនៅម៉ោង ១៤:២៦ ដល់ ១៤:២៩ គឺ<អំពីវគ្គរៀនសូត្រ>នៅថ្ងៃទី១០ <និង>ថ្ងៃទី៣០ គឺថាគេរៀនសូត្ររៀងរាល់ថ្ងៃ១០ ថ្ងៃ៣០<ជារៀងរាល់ខែ>។ តើមានប៉ុន្មានក្រុមដែរ ដែលចូលមកសិក្សារៀនសូត្រនេះ?

**ឆ៖** ពេលដែលចូលរៀនហ្នឹង ចូលរៀនទាំងអស់ ទាំងក្រុមកងចល័តក្នុងមួយក្រសួងពាណិជ្ជកម្មក្រៅប្រទេស ក្នុងប្រទេសហ្នឹង ចូលរួមទាំងអស់គ្នា រៀនថ្ងៃ១០ និងថ្ងៃ៣០ រៀន។ ថ្ងៃ១០ រៀនមួយថ្ងៃ ថ្ងៃ៣០ រៀនមួយថ្ងៃ។ រួមទាំងអស់ ទាំងក្រៅប្រទេស ទាំងក្នុងប្រទេស។

**ស៖** តើលោកស្រីអាចប៉ាន់ប្រមាណមើលមានមនុស្សប្រហែលប៉ុន្មាននាក់ចូលរួម ១០នាក់ ឬក៏ ៣០នាក់ ឬក៏១០០នាក់?

**ឆ៖** ចូលរួមក្នុងការរៀនហ្នឹងច្រើនដែរ ក្នុងក្រៅប្រទេសប្រហែលចំនួន២០នាក់។ ហើយពួកខ្ញុំនៅក្នុងកងចល័តនេះប្រហែល ៥០-៦០នាក់ដែរ។ សរុបទៅប្រហែលចូល៨០នាក់ដែរ។

[០៩:២៣:២២]

**ស៖** ខ្ញុំនឹងត្រឡប់សួរអំពីចំណុចនេះ។ កាលពីម្សិលមិញនៅពេលលោកស្រីឆ្លើយទៅនឹងសហព្រះរាជអាជ្ញានៅម៉ោង១៤:២៦នាទី លោកស្រីថា បុរសដែលក្រោយមកបានក្លាយជាប្ដីរបស់លោកស្រី

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ហើយសព្វថ្ងៃក៏នៅជាប្ដីរបស់លោកស្រីនេះ គឺថានៅពេលនោះអត់ស្គាល់លោកស្រីទេ។ ហើយលោកបន្តនិយាយថា នៅពេលដែលគេបញ្ជូនលោកស្រីទៅឲ្យរៀនសូត្រនៅថ្ងៃទី១០ និងថ្ងៃទី៣០ លោកស្រីបានឃើញគាត់។ <នៅពេលនោះកង្ហារបានផ្ទុះសេខ្សែភ្លើង ហើយគេបានចាត់ឲ្យគាត់ទៅជួសជុល។> លោកស្រីបានឃើញគាត់ ប៉ុន្តែមិនស្គាល់គាត់ទេ ពីព្រោះនៅពេលនោះគឺថាគាត់មិនបានស្នើរៀបការជាមួយលោកស្រីទេ។ លោកស្រី<សាក្សី> លោកស្រីថាមានមនុស្សជាច្រើនចូលរៀនសូត្រ នៅក្នុងវគ្គរៀនសូត្រនោះ មាន២០នាក់មកពីខាងបរទេស ហើយមាន <៨០>នាក់មកពី<ក្រុមលោកស្រី> សរុបទៅ<១០០>នាក់។ លោកស្រីបាននិយាយថា លោកស្រីមិនស្គាល់ប្ដីរបស់លោកស្រីទេ <ហើយក៏មិនបានចាប់អារម្មណ៍នឹងគាត់ដែរ>។ សំណួររបស់ខ្ញុំសួរថា ហេតុអ្វីបានជាលោកស្រី<អាចកំណត់បាន>ថាបុរសម្នាក់នេះ<គឺជាអ្នកជួសជុលកង្ហារដែលខូចនោះ>?

[០៩:២៤:២៧]

**ឆ៖** ខ្ញុំអត់បានស្គាល់គាត់មែន ប៉ុន្តែថ្ងៃនុ៎ងគណៈក្រសួងខ្ញុំហ្នឹងគាត់ហៅៗឈ្មោះ អង្កាល់ហ្នឹងភ្លើងផ្ទុះសេកង្ហារ គាត់ហៅឈ្មោះថា "មិត្តវ៉ាត់ មិត្តឯងឡើងមើលតភ្លើងនុ៎ង មើលភ្លើងនុ៎ងតិច ម៉េចបានផ្ទុះសេ?" ដល់ពេលគាត់មកស្នើខ្ញុំ ឈ្មោះ វ៉ាត់ ហ្នឹងបានខ្ញុំថាក្រសួងហ្នឹងគ្មានឈ្មោះ វ៉ាត់ ណាទេមានតែហ្នឹង អ៊ីចឹងបានខ្ញុំចាប់អារម្មណ៍ថាគាត់។ ព្រោះដែលកាលគាត់ទៅត ឡើងទៅមើលភ្លើងហ្នឹងក៏ខ្ញុំ គ្រាន់តែក្រឡែកភ្នែកទៅឃើញគាត់ដើរដែរ ប៉ុន្តែមិនចាប់អារម្មណ៍ទេ។

**ស៖** ខ្ញុំសូមបញ្ជាក់ឲ្យបានច្បាស់ វ៉ាត់ នេះដែលគេផ្សំផ្គុំឲ្យរៀបការជាមួយលោកស្រីហ្នឹង គឺជាបុរសដែលក្រោយមកក្លាយជាប្ដីរបស់លោកស្រីហ្នឹងមែនឬ?

**ឆ៖** ចាស ឈ្មោះ វ៉ាត់ ហ្នឹងហើយដែលជាប្ដីរបស់ខ្ញុំរស់នៅសព្វថ្ងៃ។

**ស៖** ហើយលោកស្រីបានឆ្លើយថាគាត់ហ្នឹងជាអ្នកស្នើសុំរៀបការជាមួយលោកស្រី។ តើលោកស្រីបញ្ជាក់ឲ្យបានលម្អិតបន្តិចបានទេ អំពីការដែលគាត់ស្នើសុំរៀបការជាមួយលោកស្រីហ្នឹង?

**ឆ៖** កាលនោះគាត់នៅអង្គភាពនៅក្រសួងពាណិជ្ជកម្មហិរញ្ញវត្ថុហ្នឹង គាត់នៅដាច់ឆ្ងាយពីពួកខ្ញុំដល់ពេលយប់មួយស្រាប់តែប្រធានកងខាងនារីខាងគាត់ហ្នឹងមក ខ្ញុំចេញពីធ្វើការសម្រិតសម្រាំងម៉ោងប្រហែលប្រាំបួនយប់ ស្រាប់គាត់ហៅខ្ញុំសួរ ហៅខ្ញុំសួរថា មិត្តអង្គការឲ្យមិត្តឯងមានគ្រួសារ តើមិត្តឯងថាម៉េចដែរ? តែអ្នកស្នើមិត្តឯងហ្នឹងគឺឈ្មោះ វ៉ាត់ នៅក្រសួងពាណិជ្ជកម្មក្រៅប្រទេស។ ខ្ញុំក៏ថាខ្ញុំរឿងគ្រួសារខ្ញុំអត់ទាន់យកទេ។ ម៉េចបានមិនយក? ខ្ញុំថាព្រោះខ្ញុំឡាក់ឡើត ខ្ញុំអត់ទាន់ចង់បានទេ ព្រោះខ្ញុំចង់

01382139



តែធ្វើការងារ ខ្ញុំអត់ទាន់ចង់បានគ្រួសារ។ ខ្ញុំឆ្លើយអ៊ីចឹងទៅ គាត់ថាគ្រួសារដែលអង្គការឲ្យមិត្តឯងរៀបនេះគឺមិត្តឯងមិនយក ក៏ត្រូវតែអង្គការរៀបឲ្យដែរ។ មិត្តឯងរស់នៅក្នុងសង្គមនេះ មិត្តឯងត្រូវតែគោរពអង្គការវិន័យ ត្រូវតែគោរពបក្ស តែបក្សដាក់ទិសមកឲ្យមិត្ត ដែលយកគ្រួសារមិត្តត្រូវតែរៀប។ ខ្ញុំឮអ៊ីចឹងក៏ខ្ញុំមិនប៉ានតវ៉ាហ្នឹងគេខ្ញុំក៏ស្ងាត់មាត់ទៅ។ ទៅក៏គេប្រាប់ថា ព្រលឹមឡើងមិត្តឯងមិនបាច់ចេញទៅធ្វើការទេ នៅហ្នឹងកន្លែងហ្នឹងផ្ទះហ្នឹងហើយ ពួកខ្ញុំដឹកខោអាវយកមកចែក។ ខ្ញុំព្រលឹមឡើងក៏ពួកខ្ញុំនេះចេញទៅស្រោចដំណាំដាំ ដូចជា ស្ពៃអីបន្តិចបន្តួចអ៊ីចឹងទៅ បានត្រលប់មកវិញ។ ប្រហែលជាម៉ោងប្រាំបួន ឃើញគេយកឡាន ដឹកឡាននឹងខោអាវហ្នឹងយកមកចែក។ មានខោអាវនោះ សំពត់មួយ អាវមួយ មានក្រមាមួយ ហើយថ្នាំដុសធ្មេញមួយដប សាប៊ូលុច្សនោះមួយដុំ ហើយនិងសាប៊ូម្សៅនោះប្រហែលកន្លះគីឡូយកមកចែក។ ខ្ញុំក៏គេហុចមក ក៏ខ្ញុំទទួលទៅ។

[០៩:២៧:៥៨]

**ស៖** បើខ្ញុំស្ដាប់មិនច្រឡំទេ អ្វីដែលលោកស្រីបានឆ្លើយគឺថា មេរបស់លោកស្រីហ្នឹងបានស្នើសុំឲ្យលោកស្រីរៀបការ។ ហើយសំណើសុំនេះ គឺស្នើដោយមនុស្សម្នាក់បុរសម្នាក់ឈ្មោះ វ៉ាត់។ តើលោកស្រីមានដែលសួរប្ដីលោកស្រីហ្នឹងទេ ក្រោយពេលរៀបការហើយនោះណា ដែលសួរប្ដីលោកស្រីថាហេតុអីបានជាប្ដីលោកស្រីស្នើសុំរៀបការជាមួយលោកស្រីទេ?

**ឆ៖** ខ្ញុំសួរគាត់ដែរ តែគាត់ថាគាត់ក៏មិនដែលស្គាល់ខ្ញុំ។ ប៉ុន្តែគាត់ថាគ្រាន់ដែលឮឈ្មោះ ដល់ពេលនេះក៏ខ្ញុំថាម៉េចបានមិត្តបងឯងមកស្នើខ្ញុំ? គាត់ថាគេប្រាប់ថាឈ្មោះ ធី១ ហ្នឹងនៅក្រសួងហ្នឹងក៏គាត់ព្រមព្រៀងស្នើទៅ។ ខ្ញុំក៏មិនសូវដឹងជាប្រវត្តិគាត់ដែរ។

**ស៖** ឥឡូវនិយាយអំពីពិធីរៀបការនេះឲ្យបានលម្អិតបន្តិច។ ម្សិលមិញនៅម៉ោង ១៤:២៥ នៅពេលឆ្លើយទៅសំណួររបស់សហព្រះរាជអាជ្ញា លោកស្រីបានឆ្លើយថា មុនថ្ងៃរៀបការ លោកស្រីបាននិយាយថាគេប្រាប់ឲ្យលោកស្រីសម្រាកកុំធ្វើការអី។ តើអ្នកណាដែលប្រាប់ឲ្យលោកស្រីឈប់សម្រាកមិនបាច់ទៅធ្វើការនោះ ដើម្បីត្រៀមរៀបការនោះ?

[០៩:២៩:៣៦]

**ឆ៖** ថ្ងៃដែលគាត់មកស្នើខ្ញុំហ្នឹងឈ្មោះ មិត្តអ៊ុម ជាប្រធានកងខាងនៅខាងក្រសួងហិរញ្ញវត្ថុហ្នឹងនៅខាងក្រៅប្រទេសហ្នឹង។ គាត់នៅខាងហ្នឹង គាត់មកស្នើ ដល់ពេលគាត់ប្រាប់ខ្ញុំហើយរួចអ៊ីចឹង ដែលខ្ញុំប្រកែកហើយក៏គាត់និយាយសព្វគ្រប់មក ក៏គាត់ប្រាប់ខ្ញុំថា “បើសិនជាស្អែកថ្ងៃស្អែកនេះថ្ងៃរៀបហើយ

សមមិត្តមិនបាច់ទៅធ្វើការទេ។ ចាំថ្ងៃប្រហែលម៉ោងប្រាំបួន ម៉ោងដប់ហ្នឹង ពួកខ្ញុំនឹងបើកអីវ៉ាន់ខោអាវហ្នឹងយកមកចែកហើយ"។ ឈ្មោះ មិត្តអ៊ុម ហ្នឹងជាប្រធាន បន្ទាប់ចុះមកក្ដាប់នៅជាន់ថ្នាក់ក្រោមទេ។

**ស៖** តើសមមិត្តអ៊ុម មានប្រាប់ទេថា វាម៉េចបានជាសំខាន់ -- មានសារៈសំខាន់ទេដែលត្រូវតែឈប់សម្រាកមិនបាច់ទៅធ្វើការ ដើម្បីត្រៀមរៀបការនេះ?

**ឆ៖** ខ្ញុំអត់ដឹងដែររឿងហ្នឹង ក៏គាត់គ្រាន់តែប្រាប់ថាអ៊ីចឹង ថា "កុំឲ្យទៅធ្វើការថ្ងៃហ្នឹង ព្រោះថ្ងៃហ្នឹង ជាថ្ងៃយើងរៀបការហើយ មិនបាច់ទៅធ្វើការទេ"។ គ្រាន់ប្រាប់តែប៉ុណ្ណឹង។

**ស៖** ម្សិលមិញនៅម៉ោង១៤:៣១នាទី លោកស្រីបាននិយាយអំពីកាលៈទេសៈនៃការរៀបការណ៎ះ! លោកស្រីបាននិយាយថា សមាជិកគ្រួសារបងប្អូន ឪពុកម្ដាយលោកស្រី មិនមានវត្តមាននៅទីនោះទេ មានវត្តមានតែប្ដីប្រពន្ធ ជាមួយនឹងអ្នកដែលគេ<រៀបចំការរៀបការ>នេះ គឺមាន តាវិទ្ធ តាហុងហើយនិងមេរបស់លោកស្រីពីរនាក់ទៀតទេដែលមានវត្តមាន។ លោកស្រីនិយាយថា ឪពុកម្ដាយ និងបងប្អូន លោកស្រីមិនមានវត្តមាននៅកន្លែងរៀបការនោះទេ។ តើបងប្អូនរបស់គូស្រករដទៃទៀត ដែលត្រូវរៀបការហ្នឹង មានវត្តមានក្នុងពេលរៀបការនោះដែរទេ?

[០៩:៣១:២៨]

**ឆ៖** ថ្ងៃរៀបការហ្នឹង ក្នុងថ្ងៃហ្នឹងអត់មានបងប្អូន ញាតិសន្ដានអីមកទេ មានតែសាមីខ្លួន និងគណៈដឹកនាំហ្នឹងទេ។ អ្នកដទៃទៀតក៏គ្មានដែរ ញាតិសន្ដានសុទ្ធតែនៅផ្ទះទាំងអស់ អត់មានដឹងថា កូនរៀបការទេ។

**ស៖** អ៊ីចឹង តើមានន័យថា ឪពុកម្ដាយ និង បងប្អូនរបស់គូស្រករដទៃទៀតទាំង<២១>គូ ហ្នឹងក៏មិនមានវត្តមានដូច បងប្អូនលោកស្រីដែរ អ៊ីចឹងមែនទេ?

**ឆ៖** ចាស អត់មានអ្នករៀបជាមួយខ្ញុំ២០គូហ្នឹង ក៏អត់មានបងប្អូន ម៉ែឪដឹងឮមកដែរ អត់មានទេ។

**ស៖** ខ្ញុំសាកល្បងសួរតាមរបៀបផ្សេង។ តើលោកស្រីដឹងថា ឪពុកម្ដាយ និងបងប្អូនរបស់គូស្រករ<២១>គូទៀត បាន<ពិភាក្សា> ឬក៏ថា បានចូលរួមសម្រេចចិត្តក្នុងការរៀបការនេះដែរឬទេ?

**ឆ៖** បងប្អូនដែល២០គូទៀតហ្នឹង អត់មានទេ។ ឪពុកម្ដាយនៅតាមសហករណ៍ទាំងអស់ សាច់ញាតិអីអត់មានចូលរួមក្នុងក្នុងកន្លែងរៀបការហ្នឹងទេ។

**ស៖** តើលោកស្រីដឹងថា ពួកគាត់ ឪពុកម្ដាយបងប្អូនទាំងអស់ហ្នឹង បានដឹងអំពីការរៀបការនេះ

ជាមុនទេ?

[០៩:៣៣:៣៨]

**ឆៈ** អត់ដឹងទេ ព្រោះគាត់នៅតាមសហករណ៍អីនោះ ព្រោះកូននៅអីទីក្រុងអីនេះ អត់មានបានផ្តល់ដំណឹងទៅឲ្យគាត់ទេ អត់មានដឹងសោះ។

**សៈ** ខ្ញុំចូលសួរសំណួរបន្ទាប់តទៀត។ ម្សិលមិញនៅម៉ោង១៤:២៨ នៅពេលឆ្លើយទៅនឹងសំណួរសហព្រះរាជអាជ្ញា លោកស្រីបានឆ្លើយថា នៅពេលនោះ លោកស្រីមិនចង់បានប្តីទេ អ៊ីចឹងបានលោកស្រីបដិសេធ។ ហើយចាប់តាំងពីឆ្នាំ១៩៧៥មក លោកស្រីបដិសេធរហូត ប៉ុន្តែដល់ឆ្នាំ១៩៧៨ លោកស្រីលែងបដិសេធបានទៀតហើយ។ <លោកស្រីចង់រស់នៅម្នាក់ឯង មិនចង់>រៀបការ<ទេ។> ក៏ប៉ុន្តែនៅថ្ងៃនោះ ទោះបីលោកស្រីបដិសេធក៏ដោយក៏អង្គការរៀបការដែរ លោកស្រីត្រូវតែគោរពទៅតាម<វិន័យ>របស់អង្គការ។ លោកស្រីនិយាយថា ចាប់តាំងពីឆ្នាំ១៩៧៥មក លោកស្រីតែងតែបដិសេធជាហូរហែ។ តើលោកស្រីចង់និយាយថាដូចម្តេចត្រង់កន្លែងនេះ?

**ឆៈ** ខ្ញុំចង់ជម្រាបថា កាលពី៧៤ ខ្ញុំនៅអីសហករណ៍ នៅកន្លែងមន្ទីរសេះសហ្នឹង គេកន្លែងគណៈស្រុកខ្ញុំហ្នឹង គាត់យកខ្ញុំទៅបង្រៀន ទៅរៀនបើកជាវគ្គនៅកន្លែងសាលាស្រុកនៅក្នុងភូមិ ឃុំខ្នុរដំបងហ្នឹង។ ដល់ពេលរៀនបានប្រហែល៣ថ្ងៃ ស្រាប់តែឃើញដឹកជនពិការនោះមកពីស្រុកព្រៃឈរនោះប្រហែលបួនប្រាំរទេះសេះ សុទ្ធតែអ្នកដាច់ដៃ ដាច់ជើង។ ដល់ពេលដឹកយកមកបាន១យប់ ស្អែកឡើងពួកខ្ញុំទៅរៀនទៀត គាត់លើកពីបញ្ហារៀបគ្រួសារ។ ដល់លើកពីបញ្ហារៀបគ្រួសារហ្នឹង គាត់ប្រាប់ពួកខ្ញុំថា គាត់មកបង្រៀនហ្នឹងផ្នែកនយោបាយពីរឿងឲ្យខ្ញុំហ្នឹងគោរពអង្គការវិន័យ គោរពបក្សយើង ដើរតាមមាគ៌ាអ៊ីចឹងទៅ ក៏គាត់ថា “ជនពិការដែលដឹកមកនេះ យកមករៀបឲ្យអ្នកទាំងអស់គ្នាហ្នឹង។ តើអ្នកទាំងអស់គ្នាហ្នឹង យល់ព្រមដែរឬអត់ទេ?” ក៏ពួកខ្ញុំអត់ហ៊ានឆ្លើយទេ។ ដល់ពេលចប់វគ្គ ជនពិការហ្នឹង ក៏គាត់បកស្រាយជាមួយអ្នកដឹកនាំថា គាត់អត់យកទេ ព្រោះនារីហ្នឹងសុទ្ធតែក្មេងៗ គាត់មិនហ៊ានយកទេ ព្រោះតែយកទៅ គាត់គ្មានអនាគតទេ។ ដល់ពេលអ៊ីចឹងទៅ ក៏ព្រមព្រៀងតាមសាមីខ្លួនខាងប្រុសទៅ ក៏ដឹកជនពិការហ្នឹងទៅមន្ទីរគាត់វិញអស់ទៅ។ ពួកខ្ញុំក៏ផុតពីត្រឹមហ្នឹងមករហូត មកទីក្រុងភ្នំពេញហ្នឹង។

[០៩:៣៦:២៣]

**សៈ** ហើយនៅពេលនេះ តើលោកស្រីមានបានបដិសេធមិនព្រមរៀបការជាមួយយុទ្ធជនពិការនោះដែរឬទេ?

**ឆះ** កាលហ្នឹងគាត់គ្រាន់តែជម្រាបជារួមនៅក្នុងសាលា។ ដល់ពេលគាត់ទៅសម្រេចខាងប្រុស ទៅខាងជនពិការហ្នឹង ក៏គាត់សុំបដិសេធមិនរៀបការទៅ ក៏គាត់អត់បានសួរទេ។ តែដែលគោលបំណង ទាំងអស់ហ្នឹង យកពួកខ្ញុំហ្នឹងទៅរៀបឲ្យជនពិការហ្នឹង។ ដល់ខាងប្រុសហ្នឹងគេបដិសេធអ៊ីចឹងទៅក៏គាត់ ក៏អត់ប៉ានមកសួរនាំទៀតដែរ ក៏នាំគ្នាដឹកគាត់ទៅអង្គភាពគាត់វិញទៅ។ ព្រោះជនពិការហ្នឹង គាត់សុទ្ធ តែអ្នករាងចាស់ៗ ហើយដាច់ដៃ ដាច់ជើង។ ដល់ពេលគាត់មកឃើញពួកខ្ញុំនៅក្មេងៗអ៊ីចឹង គាត់ថា គាត់ យកទៅក៏គ្មានអនាគតដែរ។ ដល់នេះទៅ ក៏អង្គការក៏គាត់សម្រេចថា អ៊ីចឹងមិនបាច់រៀបឲ្យទេ។

**សះ** នេះគឺអ្វីដែលកើតឡើងនៅក្នុងឆ្នាំ១៩៧៤។ ក្រោយទីក្រុងភ្នំពេញដួលរលំនៅក្នុងឆ្នាំ១៩៧៥ រហូតដល់ពេលលោកស្រីរៀបការជាមួយប្ដីលោកស្រីឈ្មោះ វ៉ាត់ នេះ តើចន្លោះពេលហ្នឹងមានគេស្នើសុំ រៀបការជាមួយលោកស្រីម្ដងណាទេ?

[០៩:៣៧:៥៥]

**ឆះ** កាលដែល៧៥ កាលហ្នឹង ខ្ញុំអត់ចាំថ្ងៃខែទេ។ នៅក្នុងអំឡុងឆ្នាំ៧៥ហ្នឹង មានខាងនារីក្ដោប ក្ដាប់ពីលើពួកខ្ញុំហ្នឹង គាត់សួរខ្ញុំពីរឿងគេស្នើនៅក្នុងទីក្រុងភ្នំពេញហ្នឹង នៅនឹងផ្សារថ្មីហ្នឹង គាត់សួរថា៖ "សមមិត្ត មានគេចង់បានសមមិត្ត តើសមមិត្តយកដែរឬអត់?" ខ្ញុំក៏ប្រាប់ទៅវិញថា៖ "ខ្ញុំនៅក្មេងណាស់ ខ្ញុំអត់ទាន់យកទេ ខ្ញុំអត់ទាន់ចង់បានគ្រួសារទេ។" តែគាត់ថា៖ "អ៊ីចឹងសមមិត្ត អត់មានគោរពអង្គការ វិន័យទេ។" ខ្ញុំថា៖ "អង្គការវិន័យគឺខ្ញុំគោរព តែខ្ញុំគោរពចំពោះតែការងារនិងធ្វើការងារទេ តែរឿង គ្រួសារ ខ្ញុំអត់ទាន់ចង់បានទេ"។ ខ្ញុំគ្រាន់ប្រាប់អ៊ីចឹងទៅ ក៏គាត់ឆ្លើយថា៖ "អ៊ីចឹងបើសមមិត្តមិនយក ក៏ខ្ញុំ ទៅជម្រាបគេវិញ។" ខ្ញុំថា៖ "ចាស ខ្ញុំអត់យកទេ។"

**សះ** តើគាត់មានប្រតិកម្មយ៉ាងម៉េចដែរ នៅពេលដែលលោកស្រីប្រាប់គាត់បែបនេះ?

**ឆះ** គាត់មានប្រតិកម្មថាឲ្យខ្ញុំប៉ុន្មានម៉ាត់ដែរ គាត់គ្រាន់ថា សមមិត្តអត់គោរពអង្គការវិន័យទេ សមមិត្តអត់មានដើរតាមមាគ៌ាទេ។ ខ្ញុំក៏អត់ប៉ានតវ៉ានឹងគេដែរ ខ្ញុំក៏សម្ងំមាត់ទៅ ក៏ឈប់តាំងពីថ្ងៃហ្នឹង ទៅ។ គាត់អត់ដែលមកសួរទៀតដែរ។

**សះ** អ៊ីចឹងគាត់<ស្ដីបន្ទោស>លោកស្រី តែក្រោយពីគាត់ជេរហើយ មានអីកើតឡើងទៀតទេ?

[០៩:៣៩:៤១]

**ឆះ** អត់មានទេ អត់មានអីកើតឡើងទៀតទេ តាំងពីហ្នឹង រហូតមកទល់នឹង៧៨ហ្នឹង។

**សះ** ឥឡូវនេះ សម្រាប់សំណួរចុងក្រោយក្នុងផ្នែកនេះ គឺខ្ញុំនិយាយអំពីគូ<២១>គូទៀត ដែល

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

លោកស្រីរៀបការជាមួយពួកគេដែរ។ ម្សិលមិញនៅម៉ោង ១៤:២២ លោកស្រីបានប្រាប់ព្រះរាជអាជ្ញាអំពីការរៀបការនៅក្នុង<ខែវិច្ឆិកា>ឆ្នាំ<៧៨>។ ហើយលោកស្រីបាននិយាយថា គូទាំងអស់ហ្នឹង គឺពួកគាត់ទាក់ទងគ្នាប្រហែលជាមួយខែពីរខែមុនម្ល៉េះ ប៉ុន្តែលោកស្រី គឺទើបតែដឹងភ្លាមនៅ១ថ្ងៃមុនប៉ុណ្ណោះ<ហើយលោកស្រីបានបដិសេធទៀត>។ ហើយនៅ<ពេលឆ្លើយជាមួយមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីនៅ>ម៉ោង<១៥:៤៥> លោកស្រីនិយាយថា <មុនពេល>ពេលរៀបការ <២០>គូដទៃទៀតហ្នឹងគេដឹងអំពីផែនការរៀបការ<មួយខែមុន>។ ដូច្នេះខ្ញុំចង់សួរឲ្យច្បាស់ នៅពេលដែលលោកស្រីនិយាយថា អ្នកដទៃទៀតនៅក្នុងក្រុមលោកស្រី គឺថាគេទាក់ទងគ្នាមុនពេលរៀបការ<មួយខែ ឬពីរខែមុន តើ>លោកស្រីចង់និយាយ<ពី២០គូផ្សេងទៀត ដែល>ពួកទាំងអស់គ្នាហ្នឹង<>រៀបការ<នៅថ្ងៃជាមួយគ្នានឹងលោកស្រីនោះដែរមែនទេ>?

[០៩:៤០:៥០]

**ឆ៖** ពួកដែល២០គូទៀតហ្នឹង ក្នុងការដែលរៀបការហ្នឹង អ៊ីចេះ កាលដែលពេលមុនរៀបការប្រហែលម្ដេ -- អេ! ប្រហែលមួយខែជាពីរខែហ្នឹង គេស្នើគ្នាមុន ចាស ចូលសួរចិត្ត សួរគំនិតគ្នា។ ប៉ុន្តែប្រុសហើយនិងស្រីហ្នឹងអត់មានជួបសម្ដីគ្នាទេ តែអ្នកដឹកនាំទេទៅសួរ។ ដល់ទៅសួរទៅ ខាងស្រីហ្នឹងក៏គេព្រមព្រៀងទៅ ក៏គេប្រាប់ទៅខាងប្រុសថាគេព្រមព្រៀងហើយ។ តែមិនទាន់កំណត់នៅថ្ងៃរៀបការទេអ៊ីចេះ។ ដល់ពេលអ្នកផ្សេងៗហ្នឹង គេចេះតែសួរគ្នាតៗរហូតទៅ។ ដល់ពេលគ្រប់២០គូហ្នឹងទៅ ស្រាប់គេកំណត់ថ្ងៃរៀបការ។ ស្រាប់ដល់ពេលកំណត់ថ្ងៃរៀបការ ខ្ញុំក៏អត់ដឹងខ្លួនដែរ ស្រាប់តែយប់ហ្នឹងស្រាប់តែគេហៅសួរទាំងយប់។ ព្រលឹមឡើងហ្នឹង ស្រាប់តែរៀបតែម្ដងហ្នឹង។

**ស៖** ឥឡូវនេះខ្ញុំសួរបន្តបន្តិចទៀត។ ខ្ញុំ<មិន>និយាយអំពីលោកស្រីទេ ប៉ុន្តែនិយាយអំពីស្ត្រី២០នាក់ទៀត ដែលចូលរួមក្នុងពិធីរៀបការហ្នឹង។ <តាមលោកស្រីយល់> តើ<>ពួកគេ<បានបង្ហាញការ>យល់ស្រប<>ប្រាប់ប្រធានកងរបស់ពួកគេ<មួយខែ>មុនពេលដែលរៀបការហ្នឹង<ទេ>? តើពួកគេមានប្រាប់បែបនេះទេ?

**ឆ៖** ពួកគេបានប្រាប់ទៅប្រធានកង គេព្រមព្រៀងយក បានជាអង្គការរៀបឲ្យគ្នា២០គូហ្នឹង។

[០៩:៤២:២៧]

**ស៖** ឥឡូវនេះខ្ញុំចង់សួរលោកស្រីបន្តិចទៀត។ តើក្នុងរបបកម្ពុជាប្រជាធិបតេយ្យ តើលោកស្រីមានស្គាល់អ្នកណាម្នាក់ដែលអាចជ្រើសរើសគូស្រករដែលពួកគេចង់បាន ហើយរៀបការបានទេ?

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** ពេលនោះអត់មានអាចថាជ្រើសរើសខ្លួនឯងបានទេ ទាល់តែខាងប្រុសគេចូលមកស្នើសុំយើង ហ្នឹងបានអាចរៀបការបាន។ បើតាមឲ្យទំនាក់ទំនងទាក់ទងគ្នាមុន អត់មានទេ។

**លោកស្រី ដូរីន ជិន៖**

សូមអរគុណលោកស្រីសាក្សី។ លោកប្រធាន ខ្ញុំអស់សំណួរហើយ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។ សូមអញ្ជើញលោកមេធាវីការពារលោក ខៀវ សំផន!

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរភាគីទាំងអស់។ ជម្រាបសួរលោក លោកស្រីចៅក្រម។ ជម្រាបសួរលោកស្រីសាក្សី។

**ស៖** ខ្ញុំមានសំណួរខ្លីបំផុតទាក់ទងទៅនឹងអ្វីដែលលោកចៅក្រម ឡាវ៉ែន៍ បានសួរលោកកាលពីព្រឹក -- លោកស្រីកាលពីព្រឹកមិញ។ លោកស្រីបាននិយាយអំពីការដែលលោកស្រីបានបង្រៀនទៅកុមារមួយចំនួន នៅពេលដែលលោកស្រីទទួលបន្ទុកខាងបង្រៀន។ គេបានសុំឲ្យលោកស្រីប្រាប់ទៅកុមារហ្នឹងថាឲ្យប្រយ័ត្នខ្លាំង។ <ហើយលោកស្រីបាន>និយាយថា <វាព្រោះតែ>មានគេបោកគ្រាប់បែកនៅក្រសួងពាណិជ្ជកម្ម។ អ៊ីចឹងលោកស្រីអាចបញ្ជាក់បានទេ<ពី>ព្រឹត្តិការណ៍<ដែលលោកស្រីនិយាយនោះ ហើយតើលោកស្រីបានឮអ្វីខ្លះពាក់ព័ន្ធនឹងរឿងនោះ>?

[០៩:៤៤:១៩]

**លោកស្រី ផាន់ ហ៊ីម៖**

**ឆ៖** ក្នុងក្រសួងពាណិជ្ជកម្មហ្នឹង អត់មានទេ។ ដែលខ្ញុំនិយាយនេះ នៅតាមសហករណ៍ នៅឯស្រុកនោះ ឯកន្លែងសេះស។ តែកន្លែងមន្ទីរពួកខ្ញុំនៅហ្នឹង នៅក្នុងព្រៃ។ តែរយៈកាលកន្លងមកមានគិញធ្វើជាគោ ហើយហៅកាប៉ាល់ហោះមកទម្លាក់គ្រាប់បែកនៅក្បែរមន្ទីរហ្នឹង។ តែដល់ម្ល៉ោះហើយ គេឲ្យយើងអប់រំកុមារហ្នឹងដូចថា នៅពេលចេញដើរទៅក្រៅអីឲ្យប្រយ័ត្នប្រយែង ខ្លាចខ្លាំង ខ្លាចអ៊ីចឹង។ បើឃើញចម្លែក ឲ្យមករាយការណ៍។ តែក្នុងក្រសួងពាណិជ្ជកម្ម នៅក្នុងទីក្រុងភ្នំពេញនេះអត់មានទេ។

**ស៖** អ៊ីចឹងសហករណ៍ហ្នឹងសហករណ៍មួយណាដែរ? ហើយសហករណ៍ហ្នឹងនៅឯណាដែរ?

**ឆ៖** នៅមន្ទីរសេះស។ នៅមន្ទីរសេះសហ្នឹងនៅជាប់ថ្នល់ជាតិ គេហៅថាកន្លែងសេះសហ្នឹង

មានខ្លោងទ្វារមួយ ហើយពួកខ្ញុំនៅខាងលិចផ្លូវចុះទៅខ្នុរដំបង នៅក្នុងព្រៃ។

**ស៖** តាមចម្លើយពីមុនរបស់លោកស្រីហ្នឹង លោកស្រីបាននិយាយពីយន្តហោះមួយ។ លោកស្រីបានឃើញយន្តហោះហ្នឹង ឬយ៉ាងម៉េច ឬក៏ឮស្នូរសំឡេងយន្តហោះហ្នឹង ឬយ៉ាងម៉េច?

[០៩:៤៥:៥៨]

**ឆ៖** យន្តហោះហ្នឹងមកទម្លាក់ក្បែរមន្ទីរពួកខ្ញុំនៅហ្នឹង។ កាលហ្នឹងខ្ញុំនៅចម្ងាយប្រហែល២០០ម៉ែត្រពីកន្លែងទម្លាក់គ្រាប់បែកហ្នឹង។ កាលហ្នឹងខ្ញុំ -- កាលពីមុនវាទម្លាក់គ្រាប់បែកហ្នឹង ខ្ញុំឃើញកងឈ្លបមកកាប់ទប់ផ្លូវថ្នល់ហ្នឹង ព្រោះផ្លូវហ្នឹងមានស្ពាន ដល់ដាច់ផ្លូវទៅ ឃើញគេកេណ្ឌកងឈ្លបតាមភូមិហ្នឹងមកឱ្យធ្វើស្ពានហ្នឹង។ ចាស ដល់ធ្វើៗទៅ ស្រាប់តែថ្ងៃមួយស្រាប់តែមានកប៉ាល់ហោះស្ពាបកាត់មួយគូរទៅ ក្រឡឹងៗតែពីរជុំ ចាក់ទម្លាក់គ្រាប់បែកម្ដុំកន្លែងត្រង់ហ្នឹងទៅ។ ម្ល៉ោះហើយបានជាកន្លែងពួកខ្ញុំហ្នឹងថាឱ្យរៀបការពារតាមដាន ព្រោះមានខ្មាំង មានគិញ វាបង្កប់ខ្លួនអ៊ីចឹង វាធ្វើជាគោ ព្រោះកាលមួយថ្ងៃមួយកងឈ្លបហ្នឹងគាត់និយាយថា គាត់ធ្វើឱ្យឃើញគោនោះ បោលកាត់ថ្នល់នោះ ឆ្លងទៅក្នុងព្រៃធំ ទៅខាងជើង រំលងបានប្រហែល៣ថ្ងៃហ្នឹង ឃើញកប៉ាល់ហោះហ្នឹងមកទម្លាក់នៅកន្លែងហ្នឹង។ ខ្ញុំគ្រាន់តែឮគាត់និយាយតែប៉ុណ្ណឹងទេ ពីរឿងហេតុការណ៍អីទៀត គឺខ្ញុំអត់បានដឹងដែរ។

**ស៖** តើលោកមានចាំដែរឬទេថា ហេតុការណ៍ហ្នឹងកើតឡើងនៅពេលណាដែរ?

**ឆ៖** ខ្ញុំភ្លេចហើយតាំងពីឆ្នាំ៧៤ម្ល៉េះ។

**ស៖** អ៊ីចឹងគឺ បានន័យថាមុនពេលបែកភ្នំពេញ អ៊ីចឹងណ៎ា?

**ឆ៖** ចាស ព្រឹត្តិការណ៍នេះកើតឡើងនៅពេលមុនបញ្ជូនពួកខ្ញុំមកត្រៀមនៅសមរភូមិ។

[០៩:៣៨:១១]

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន ខ្ញុំអស់សំណួរហើយលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។ សវនាការស្ដាប់សក្ខីកម្មសាក្សី ផាន់ ហ៊ឹម ដល់ទីបញ្ចប់ហើយ អង្គជំនុំជម្រះអរគុណលោកស្រី ដែលបានចំណាយពេលវេលាមកផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ក្នុងឋានៈជាសាក្សីអស់រយៈពេល២ថ្ងៃមកនេះ។ លោកស្រីអាចត្រឡប់ទៅវិញបានហើយ។ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ក្នុងការជូនលោកស្រី

ផាន់ ហ៊ឹម វិលត្រឡប់ទៅវិញ។

ដូចដែលអង្គជំនុំជម្រះបានជូនដំណឹងទៅភាគីរួចហើយតាមរយៈអ៊ីម៉ែល។ មន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះកាលពីថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៦ថា បន្ទាប់ពីបញ្ចប់ការស្តាប់សក្ខីកម្មសាក្សី ផាន់ ហ៊ឹម អង្គជំនុំជម្រះនឹងស្តាប់សារណាផ្ទាល់មាត់របស់ភាគីទាក់ទងនឹងការកោះហៅបុគ្គលដែលមានរហស្សនាម 2-TCE-93។ អង្គជំនុំជម្រះក៏បានស្នើឲ្យភាគីផ្តល់មតិយោបល់លើបញ្ហាចំនួនពីរ គឺ ១) ថាតើមេធាវីការពារក្តីលោក នួន ជា និងសហព្រះរាជអាជ្ញានៅតែរក្សាសំណើសុំក្នុងការស្តាប់សក្ខីកម្ម 2-TCE-93 ទៀតដែរឬទេ? ២) ប្រសិនបើមេធាវីការពារក្តី នួន ជា និងសហព្រះរាជអាជ្ញានៅតែមានបំណងស្តាប់សក្ខីកម្មរបស់គាត់ ថាតើមេធាវីការពារក្តី លោក នួន ជា និងសហព្រះរាជអាជ្ញាស្នើឲ្យស្តាប់សក្ខីកម្មរបស់គាត់ទៅលើអង្គហេតុជាក់លាក់ណាខ្លះ? ដោយសារតែមានភាពមិនច្បាស់លាស់ពាក់ព័ន្ធទៅនឹងតួលេខនៅក្នុងរបាយការណ៍របស់គាត់ ហេតុដូច្នេះអង្គជំនុំជម្រះស្នើឲ្យភាគីធ្វើការបញ្ជាក់ថាតើសក្ខីកម្មរបស់គាត់នឹងសមស្របសម្រាប់បញ្ជាក់ពីអង្គហេតុទាំងនេះយ៉ាងដូចម្តេចវិធាន៨៧(៣)(គ) នៃវិធានផ្ទៃក្នុង។

ជាដំបូង អង្គជំនុំជម្រះសូមប្រគល់វេទិកាដល់តំណាងសហព្រះរាជអាជ្ញាឆ្លើយតបចំពោះបញ្ហានេះ។ សូមអញ្ជើញ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោក លោកស្រី ចៅក្រម។ សហព្រះរាជអាជ្ញាយល់ឃើញនៅពេលនេះថា <>យើងគិតថាវាមិនចាំបាច់ក្នុងការកោះហៅ 2-TCE-93 មកនោះឡើយ។ ព្រោះថាផ្អែកទៅតាមអនុស្សរណៈក៏ដូចជាការជូនដំណឹង គឺថាយើងខ្ញុំយល់ឃើញថា វាជាដំណាក់កាលចុងក្រោយនៃសវនាការហើយ ហើយអនុស្សរណៈក៏បានបញ្ជាក់ថា <>សាក្សីអ្នកជំនាញ<បានស្នើសុំធ្វើការវិភាគបន្ថែមដែលនឹងត្រូវការពេលដល់ទៅរាប់ខែឯណោះ>។ ដូច្នេះ យើងខ្ញុំយល់ឃើញថាមិនគួរមានការពន្យារពេលបន្ថែមក្នុងការផ្តល់ព័ត៌មានបន្ថែមទៅលើអ្វីដែលយើងមានពីមុនរួចមកហើយនោះទេ។ ដូច្នេះ យើងខ្ញុំចង់ឲ្យមានការបញ្ចប់សវនាការនេះឲ្យបានឆាប់រហ័ស។

[០៩:៥១:៥៥]

ទី២គឺតាមការសង្កេតរបស់អង្គជំនុំជម្រះ គឺនិយាយអំពីភាពមិនប្រាកដប្រជា។ ខ្ញុំសូមកត់សម្គាល់ថា ការវិភាគផ្នែកប្រជាសាស្ត្រណាមួយហ្នឹង គឺមានភាពមិនប្រាកដប្រជា ទោះជាក្នុងករណីណាក៏

ដោយ។ គឺថាវាអាចមានបញ្ហាមួយចំនួន គឺថាទិន្នន័យរបស់ទិន្នន័យប្រជាសាស្ត្រតែងតែមានភាពមិនច្បាស់លាស់។ ដូច្នេះ អ្វីដែលយើងខ្ញុំកត់សម្គាល់ឃើញគឺថារបាយការណ៍នេះ គឺថា<មិន>ផ្អែកទៅតាមទិន្នន័យដើម <>របស់អ្នកនិពន្ធផ្ទាល់ទេ ប៉ុន្តែវាជាការប្រមូលផ្តុំការវិភាគផ្សេងៗទៀត ដែលទទួលបានពីឯកសារដទៃទៀតនុំង គឺថាការវិភាគទៅលើទិន្នន័យប្រជាសាស្ត្រទាំងអស់នោះ <ដែលបានស្រាវជ្រាវអំពីចំនួនអ្នកស្លាប់ពីសម័យ>កម្ពុជាប្រជាធិបតេយ្យ<>។ ខ្ញុំគិតថាចំណុចទាំងអស់នេះវាមានភាពពាក់ព័ន្ធដោយសារតែអ្នកនិពន្ធខ្លួនឯងផ្ទាល់មិនបានអនុវត្ត មិនបានពឹងផ្អែកទៅលើប្រភពព័ត៌មានរបស់គាត់ដែលបានស្រាវជ្រាវទេ ប៉ុន្តែគាត់ពឹងផ្អែកទៅលើប្រភពព័ត៌មានដទៃទៀតដែលគាត់ប្រមូលផ្តុំបាន។ ហេតុដូច្នេះហើយ ខ្ញុំគិតថា ចំពោះយើងខ្ញុំការស្តាប់សក្ខីកម្មផ្ទាល់ពីអ្នកជំនាញ ហាក់ដូចជាមិនបានផ្តល់អ្វីបន្ថែមលើសពីរបាយការណ៍ដែលមានស្រាប់រួចទៅហើយនោះទេ។

ខ្ញុំខាងសហព្រះរាជអាជ្ញាយល់ឃើញថា វាមិនចាំបាច់ក្នុងការកោះហៅសាក្សីអ្នកជំនាញនេះមកផ្តល់សក្ខីកម្មឡើយ ប៉ុន្តែយើងមិនជំទាស់នោះឡើយ ប្រសិនបើអង្គជំនុំជម្រះយល់ឃើញថាសក្ខីកម្មរបស់អ្នកជំនាញនេះអាចមានប្រយោជន៍ទៅដល់អង្គជំនុំជម្រះ។ <ប៉ុន្តែនៅពេលនេះយើងយល់ឃើញថា វាមិនចាំបាច់ឡើយ។> សូមអរគុណ។

[០៩:៥៤:០១]

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោកព្រះរាជអាជ្ញា។

ជាបន្តសូមអញ្ជើញលោកមេធាវីការពារក្តីលោក នួន ជា មានយោបល់លើបញ្ហានេះ។

**លោក វ៉ិចទ័រ កូប៉េ៖**

ដោយសារតែសហការីរបស់ខ្ញុំគាត់ទាបអ៊ីចឹងដូច្នេះ ខ្ញុំត្រូវសារេមីក្រូបន្តិចសិន សូមទោសលោកប្រធាន។ សូមជម្រាបសួរលោកប្រធាន លោក លោកស្រី ចៅក្រម។ ការពិតទៅ គឺថាយើងខ្ញុំមានព័ត៌មានច្រើនគួរសមដែរ ដែលត្រូវលើកមកនិយាយនៅពេលនេះ ជាពិសេសពាក់ព័ន្ធទៅនឹងបញ្ហាថា តើអ្នកជំនាញប្រជាសាស្ត្រហ្នឹងគួរមកផ្តល់សក្ខីកម្មឬក៏អត់នោះ។ ដូចដែលអង្គជំនុំជម្រះបានជ្រាបរួចទៅហើយ <ប៉ុន្តែមិនសំខាន់សម្រាប់>សាធារណជន<ទេ គឺថាមានប្រវត្តិសវនាការដ៏វែងឆ្ងាយទាក់ទងនឹង>អ្នកជំនាញនេះ<>។ ដូច្នេះខ្ញុំគិតថាយើងគួរតែជម្រាបឲ្យអ្នកទាំងអស់គ្នាដឹងថា មេធាវីការពារក្តីនួន ជា ក្នុងខែតុលា ឆ្នាំ២០០៨ គឺប្រហែលជា៨ឆ្នាំមុនម្ល៉េះ បានស្នើសុំឲ្យមានអ្នកជំនាញប្រជាសាស្ត្រ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ដើម្បីចាត់តាំងមកទីនេះ។ ប៉ុន្តែអ្វីដែលយើងចង់បញ្ជាក់គឺថា បញ្ហាប្រជាសាស្ត្រគឺជាបញ្ហាដ៏សំខាន់មួយសម្រាប់ក្រុម នួន ជា ព្រោះថាយើងមានហេតុផលជាច្រើន ហើយខ្ញុំនឹងមិននិយាយលម្អិតនៅពេលនេះទេ ព្រោះថាយើងមិនទទួលយកនូវបារ៉ាម៉ែតដែលកំណត់ដោយអ្នកជំនាញប្រជាសាស្ត្រកន្លងមកនោះទេ។ យើងខ្ញុំគិតថាចំនួននៃអ្នកស្លាប់ដោយផ្ទាល់ក្តី ដោយប្រយោលក្តី ដែលកើតឡើងដោយរបបកម្ពុជាប្រជាធិបតេយ្យ គឺថាយើងយល់ឃើញថាចំនួនទាំងអស់នោះគឺវាច្រើនជ្រុលហួសហេតុ។ <មានរបាយការណ៍ផ្សេងៗទៀត> ដែលគួរឲ្យជឿជាក់ច្រើនជាងនេះ។ ដោយយើងខ្ញុំធ្វើការសង្ខេបដោយខ្លីអំពីប្រវត្តិហ្នឹង គឺដោយសារប្រវត្តិហ្នឹងហើយ ទើបយើងស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេតចាត់តាំង<>អ្នកជំនាញប្រជាសាស្ត្រមួយ។ ហើយពួកគេបានធ្វើនៅក្នុងឆ្នាំ២០០៩។ អ្នកជំនាញនោះគឺជាអ្នកជំនាញដែលយើងកំពុងតែជជែកនៅពេលនេះ ហើយអង្គជំនុំជម្រះក៏បានដឹងដែរថា អ្នកជំនាញហ្នឹងបានមកផ្តល់របាយ-ការណ៍ ហើយមិនមែនតែក្រុម នួន ជា ទេដែលស្នើសុំ សូម្បីខាងក្រុម អៀង សារី ក៏បានស្នើសុំ។ ហើយឥឡូវនេះក្រុមខាង ខៀវ សំផន <ក៏ស្នើសុំដែរ ហើយមានការ>រិះគន់មួយចំនួនដែរ ទាក់ទងទៅនឹងកំហុសឆ្គងក្នុងវិធីសាស្ត្រស្រាវជ្រាវ។ ប៉ុន្តែមានបញ្ហាមួយចំនួនកើតឡើង<>ដោយសារឯករាជ្យភាពនិងភាពមិនលម្អៀងរបស់គាត់ ដោយសារគាត់ជាបុគ្គលិករបស់ខាងព្រះរាជអាជ្ញានៅ អាយ.ស៊ី.ធី.វ៉ាយ។ បញ្ហានេះត្រូវបានជជែកគ្នាមួយសាហើយនៅដំណាក់កាលមុន នៅអង្គបុរេជំនុំជម្រះ។

[០៩:៥៧:៤៩]

អ្វីដែលខ្ញុំចង់ជម្រាបនេះ គឺដើម្បីឲ្យភាគី ក៏ដូចជាអង្គជំនុំជម្រះបានជ្រាបអំពីប្រវត្តិកន្លងមក។ ហើយយើងធ្លាប់ដាក់សំណើសុំចំនួន២៦ សុំបំពេញកិច្ចស៊ើបសួរ ហើយនិងបានស្នើសុំឲ្យខាងក.ស.ច.ស ធ្វើការតែងតាំងនៃអ្នកជំនាញទី២។ ដោយសារតែយើងមានហេតុផលច្រើនដែលយើងគិតថាវាជារឿងចាំបាច់មួយ។ <មាន>សេចក្តីសម្រេចគួរឲ្យ<>ចាប់អារម្មណ៍មួយផងដែរ។ ហើយ<យើងអាចរកអានបាន និងមានប្រយោជន៍ គឺ>សេចក្តីសម្រេចពីចៅក្រម យូ ប៊ុនឡេង ហើយនិងចៅក្រម ម៉ាកសែលឡឺម៉ុងដ៍ គឺឯកសារ D356/1 ដែលទឡ្ហីករណ៍ទាំងអស់ត្រូវបានសង្ខេប ហើយជាលទ្ធផលត្រូវបានបដិសេធនូវសំណើរបស់យើង។ ដោយសារតែមានប្រវត្តិនិងមានបញ្ហាទាំងអស់នេះហើយ ទើបនៅក្នុងសវនាការ ០០២/០១ យើងបានដាក់សំណើសុំឲ្យសាក្សីនេះមកផ្តល់សក្ខីកម្ម ក្នុងនាមជាសាក្សី <ឬ> អ្នកជំនាញបន្ត។ ដូចដែលយើងបានដឹង<មកហើយ គឺថារឿងនោះមិនបានកើតឡើង>នៅក្នុងសំណុំរឿង០០២/០១<ទេ។> អ្វីដែលបានកើតឡើងនោះគឺថា អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសាលក្រម

របស់ខ្លួន នៅពេលដែលធ្វើការសម្រេចទៅលើអង្គហេតុបានៗលើកអំពីចំនួនស្លាប់ដ៏ច្រើនលើសលប់ហួសហេតុ ពីចំនួន ១,៥លាន ទៅ ២លាននាក់ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ គឺខ្ញុំយោងទៅលើកថាខណ្ឌ ១៧៤ របស់សាលក្រមសាលាដំបូង។ យើងបានប្ដឹងសាទុក្ខទៅលើការសម្រេចលើអង្គហេតុនេះរួចទៅហើយ។

[០៩:៥៩:៥៧]

នៅក្នុងឯកសារ F16 ដែលជាបណ្ដឹងសាទុក្ខរបស់យើងខ្ញុំនៅក្នុងកថាខណ្ឌ២២២, ២២៣, ២២៤ ដែលយើងបានជំទាស់ ហើយខ្ញុំសូមដកស្រង់៖ "គឺមានកំហុសផ្នែកអង្គច្បាប់យ៉ាងច្រើន ដែល<រំលោភសិទ្ធិ>កូនក្ដីយើងខ្ញុំ<ក្នុងការ>ទទួលបានការ<ជូនដំណឹងដ៏ត្រឹមត្រូវ អំពីការ>ចោទប្រកាន់ទៅលើឧក្រិដ្ឋកម្ម <និងការតទល់នឹងភស្ដុតាងប្រឆាំងនឹងរូបគាត់>។ យើងជឿជាក់ថា ការសម្រេចរបស់អង្គជំនុំជម្រះទាក់ទងទៅនឹងចំនួនមនុស្សដែលត្រូវបានចោទថាបានស្លាប់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺជាចំនួនដែលមិនសមស្របត្រឹមត្រូវ។" យើងក៏បានជំទាស់ផងដែរថា វាមានកំហុសបន្ថែមទៀត គឺខ្ញុំយោងកថាខណ្ឌ២២៤ ហើយខ្ញុំសូមដកស្រង់ចេញពីកថាខណ្ឌនេះ៖ "ជាជម្រើសមួយទៀត អង្គជំនុំជម្រះសាលាដំបូងមានកំហុសលើអង្គហេតុ ដោយធ្វើការសម្រេចថា មានមនុស្សប្រហែលជាចន្លោះពី ១,៥លាន ទៅ ២លាននាក់ បានស្លាប់ដោយផ្អែកទៅលើកំណត់ត្រាដែលមានចំនួនកម្រិតមួយប៉ុណ្ណោះ។ <>យើងយល់ឃើញថា <អង្គជំនុំជម្រះខ្លួនឯងហ្នឹងបានកត់សម្គាល់ឃើញ ចំនួនប៉ាន់ស្មាននៃអ្នកស្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ>គឺ<>មានចន្លោះពី ៦០០.០០០ ទៅដល់ ៣លាន ជាចំនួនដែលច្រើន។ <ខ្ញុំសូមដកស្រង់ម្ដងទៀត>"វា<ជាការមិនសមទំនងដែល>សន្និដ្ឋានថា<អ្នកស្លាប់>មានចំនួន<ខុសគ្នាចន្លោះ> ២,៤លាននាក់ ដែលស្ថិតនៅក្នុងគម្លាតខ្ពស់ និងទាបបំផុតនោះ"។ ហើយយើងខ្ញុំសង្ឃឹមថា អង្គជំនុំជម្រះតុលាការកំពូលនឹងចេញនូវសាលដីកាលើកំហុសអង្គហេតុ និងកំហុសអង្គច្បាប់នេះ។

[១០:០១:៥១]

ដូច្នេះ ខ្ញុំបានពិភាក្សារួចហើយអំពីការជំទាស់អង្គហេតុ និងអង្គច្បាប់បែបនេះ ប៉ុន្តែខ្ញុំក៏សូមបញ្ជាក់ផងដែរថា ហើយនេះក៏ជាការឆ្លើយតបទៅនឹងសហព្រះរាជអាជ្ញាដែលថា នៅក្នុងឆ្នាំ២០១៥ យើងបានស្នើសុំអង្គជំនុំជម្រះឲ្យពន្លឿនការបង្ហាញខ្លួនរបស់សាក្សីអ្នកជំនាញមួយនេះ គឺនៅក្នុងផ្នែកការប្រព្រឹត្តទៅលើជនជាតិចាម ជនជាតិវៀតណាម ដោយសារយើងយល់ឃើញថា វាជាការចាំបាច់ ដើម្បី

01382150



ឲ្យកោះហៅគាត់មកក្នុងនាមជាអ្នកជំនាញ។

អង្គជំនុំជម្រះប្រហែលជាជ្រាបហើយថា សំណើរបស់យើងត្រូវបានបដិសេធចោល។ ទើបមកដល់ពេលឥឡូវនេះ ដែលយើងឈានដល់ដំណាក់កាលមួយដែលវាជិតដល់ពេលបញ្ចប់កិច្ចដំណើរការនីតិវិធីរួចទៅហើយ។ ហើយវាអាចមានការលំបាកក្នុងការឲ្យគាត់មកផ្តល់សក្ខីកម្មនៅពេលនេះ។ ខ្ញុំគិតថា វាជារឿងគួរឲ្យសោកស្តាយ ដោយសារតែយើងចំណាយពេល៨ឆ្នាំរួចមកហើយ ដែលយើងតវ៉ាអំពីបញ្ហាប្រជាសាស្ត្រនេះ។ ដូច្នេះហើយវាមិនមានអ្វីគួរឲ្យសង្ស័យទៀតនោះទេ លោកប្រធាន គឺថាបញ្ហាប្រជាសាស្ត្រ បញ្ហាថាតើមនុស្សប៉ុន្មាននាក់ស្លាប់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ <ប៉ុន្តែវាក៏សំខាន់ដែរក្នុងការដឹងថា តើមាន>មនុស្សប៉ុន្មាននាក់ស្លាប់ចន្លោះពីឆ្នាំ៧០ ដល់៧៥ និងក្រោយឆ្នាំ៧៩ ដែលវាជាបញ្ហាដ៏សំខាន់ សម្រាប់មេធាវីការពារក្តី។

[១០:០៣:៥០]

ដូច្នេះថាតើយើងគួរទៅផ្លូវមួយណា? យើងត្រូវចាំថា 2-TCE-93 ប្រសិនបើគាត់មិនមានគុណវុឌ្ឍិជាអ្នកជំនាញទេ យើងគិតថា វាជាការល្អមួយ ប្រសិនបើយើងរើសជម្រើសផ្សេង។ ដូច្នេះ យើងចង់ដឹង <>គឺថាអាចអង្គជំនុំជម្រះជាការស៊ើបអង្កេតបន្ថែម ថាតើអ្នកជំនាញណាម្នាក់ដែលអាចមកផ្តល់សក្ខីកម្មក្នុងនាមជាអ្នកជំនាញ។ ខ្ញុំគិតថា មានម្នាក់ទៀតដែលមានជនជាតិបារាំង គាត់កំពុងបង្រៀននៅសាកលវិទ្យាល័យកាលីហ្វ័រញ៉ា ហើយគាត់បោះពុម្ពឯកសារមួយនៅក្នុងឆ្នាំ២០១៥ អំពីចំនួនមនុស្សស្លាប់ដ៏ច្រើនលើសលប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ហើយប្រហែលជាគាត់អាចមកផ្តល់សក្ខីកម្ម ដើម្បីបញ្ជាក់ គឺខ្ញុំនិយាយយោងទៅលើបុគ្គលម្នាក់ឈ្មោះ ប៉ាទ្រីក អេវើលីន។ គាត់បានសរសេរអត្ថបទមួយនៅក្នុងឆ្នាំ២០១៥ ដែលនិយាយអំពីរយៈពេលក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងរយៈពេលមុននិងក្រោយកម្ពុជាប្រជាធិបតេយ្យ។ <វាជាអត្ថបទមួយដែលអ្នកជំនាញផ្សេងទៀតត្រូវបានគេគិតថាយកមកពិចារណា ដើម្បី>ធ្វើបច្ចុប្បន្នភាពបន្ថែម<លើរបាយការណ៍របស់គាត់>។ <ដូច្នេះសំណួរគឺថាដោយពិចារណាទៅលើសារៈសំខាន់នៃប្រធានបទរបស់ក្រុមមេធាវីការពារក្តីលោក នួន ជា ហេតុអ្វីបានជាមិនផ្លាស់ប្តូរ> មិនកោះហៅ 2-TCE-93 ទេ <ប៉ុន្តែជំនួសមកវិញ ដោយពិចារណាទៅលើការជាប់ពាក់ព័ន្ធរបស់គាត់ថ្មីៗនេះក្នុង>ការស្រាវជ្រាវ<ពីប្រជាសាស្ត្រ>ក្នុងរបបកម្ពុជាប្រជាធិបតេយ្យផងនោះ <> យើងអាចហៅ ប៉ាទ្រីក អេវើលីន មក<ធ្វើជាអ្នកជំនាញ>បាន។ ខ្ញុំយល់ឃើញថា លោកសាស្ត្រាចារ្យហ្នឹងគាត់ឈានទៅដល់ការសន្និដ្ឋានមួយដែលខាងមេធាវីការពារក្តីមិនគាំទ្រទេ ប៉ុន្តែយើងគួរតែឲ្យ

សាធារណជនបានឮនូវសេចក្តីសន្និដ្ឋានរបស់គាត់។

[១០:០៦:១២]

ខ្ញុំបញ្ជាក់ឡើងវិញ គឺថាវាមានរយៈពេលជិត៩ឆ្នាំមកហើយ នៅពេលដែលគេចាប់ផ្តើមធ្វើការជំនុំជម្រះទៅលើកូនក្តីរបស់ខ្ញុំ ប៉ុន្តែមិនមានការពិភាក្សាជាសាធារណៈនៅក្នុងសាលសវនាការនេះអំពីថាតើមនុស្សប៉ុន្មាននាក់ដែលស្លាប់ដោយសារគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យ និងថាតើមានមនុស្សប៉ុន្មាននាក់ត្រូវបានស្លាប់ដោយ<អំពើហិង្សា និងប៉ុន្មាននាក់ស្លាប់>ដោយប្រយោលជាដើម។ យើងទទួលស្គាល់ថា វាមានភាពមិនប្រាកដប្រជាច្រើន ប៉ុន្តែខ្ញុំគិតថាវាមានប្រយោជន៍មួយដែលថា យើងគួរតែលើកយកបញ្ហានេះមកដេញដោលពិភាក្សាជាសាធារណៈ។ យើងដឹងថាយើងត្រូវស្វែងរកយុត្តិធម៌ ប៉ុន្តែក៏ត្រូវមើលថាតើយើងស្វែងរកយុត្តិធម៌ដោយរបបណាដែរ។ ខ្ញុំគិតថានេះជាការជូនដំណឹងខ្លី ប៉ុន្តែដោយសារតែប្រវត្តិនីតិវិធី ក៏ដូចជាដោយសារសារៈសំខាន់នៃប្រធានបទនេះចំពោះមេធាវីការពារក្តី នួន ជា ខ្ញុំសូមស្នើសុំឲ្យមានការពិចារណាឡើងវិញដោយអង្គជំនុំជម្រះសាលាដំបូង <ជំនួសឲ្យ>ការកោះហៅ 2-TCE-93 <គួរតែ>កោះហៅលោកសាស្ត្រាចារ្យ ប៉ាទ្រីក អេវើលីន ដែលបង្រៀននៅសាកលវិទ្យាល័យកាលីហ្វ័រញ៉ា។

ចំណុចមួយចុងក្រោយដែលខ្ញុំចង់បន្ថែម ដែលថាខ្ញុំភ្លេចនិយាយនៅមុននេះ គឺអំពីសារៈសំខាន់នៃការផ្តល់សក្ខីកម្មដែលអ្នកជំនាញទៅលើបញ្ហាប្រជាសាស្ត្រ ព្រោះថាសក្ខីកម្ម ព្រោះថាបញ្ហានេះគឺជាការបន្ថែមទៅលើអ្វីដែលសាក្សីអ្នកជំនាញមួយរូបផ្សេងទៀតបានបដិសេធមិនមកផ្តល់សក្ខីកម្ម។ <ការសន្និដ្ឋានជាច្រើន>របស់ ម៉ែខល វីកឃើរី <ជាសេចក្តីសន្និដ្ឋាន>ដែល<>មេធាវីការពារក្តីយល់ស្រប <ជាពិសេស>ការសន្និដ្ឋាន <ពាក់ព័ន្ធនឹងចំនួន>ចំនួនជនជាតិចាមដែលបានស្លាប់។ យើងបានត្រៀមរៀបចំរួចហើយសម្រាប់គាត់។ យើងត្រៀមសំណួរជាច្រើនសម្រាប់គាត់ ដែលយើងធ្វើការប៉ាន់ប្រមាណដែលថា៨០ភាគរយគឺសំណួររបស់យើងទាក់ទងទៅនឹងប្រជាសាស្ត្រ ប៉ុន្តែគាត់មិនបានមកផ្តល់សក្ខីកម្មនោះទេ។ នេះហើយគឺជាហេតុផលបន្ថែមមួយទៀត ដែលយើងចាំបាច់ មុនពេលដែលយើងបញ្ចប់សវនាការលើភស្តុតាង ឲ្យមានសាក្សីមួយ -- សាក្សីអ្នកជំនាញមួយរូបទៅលើបញ្ហាប្រជាសាស្ត្រ ដើម្បីមកផ្តល់សក្ខីកម្មនៅទីនេះ<ហើយឆ្លើយរាល់សំណួរទាំងអស់ដែលនៅសេសសល់>។ បាទ សូមអរគុណ។

[១០:០៨:៤៧]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំចង់សួរសំណួរទៅលោក។ ទី១ គឺថា ប្រាកដណាស់ថា នៅក្នុង<បរិបទនៃ>សវនាការនេះ យើងមានប្រធានបទជាច្រើនដែលយើងត្រូវជជែកដេញដោល ប៉ុន្តែយើងគួរតែផ្តោតទៅលើប្រធានមួយចំនួនដែលទាក់ទងផ្ទាល់ផ្នែកអង្គច្បាប់។ ហើយអាចថា យើងមិនគួរជជែកអំពីបញ្ហាប្រវត្តិសាស្ត្រ ឬក៏មិនពាក់ព័ន្ធដោយផ្ទាល់នៅក្នុងសវនាការនេះឡើយ។ ដូច្នេះ ខ្ញុំចង់<ផ្តង់>ការ<ពិភាក្សាទាំងមូលនេះទៅលើភាពគួរឲ្យចាប់អារម្មណ៍។ វាគួរតែត្រូវបានពិភាក្សា ហើយ>សាធារណជនគាត់ត្រូវដឹងអំពីបញ្ហាអង្គច្បាប់ជាដើម។ នេះជាមតិបឋមរបស់ខ្ញុំ។ ខ្ញុំចង់សួរលោកមេធាវី តើលោកមានបានអាន<អត្ថបទ> របស់លោកសាស្ត្រាចារ្យហ្នឹងទេ ថាតើ<ចំណុចណាមួយដែលលោកគិតថាត្រូវការការ>បញ្ជាក់<បន្ថែមនោះ?> ខ្ញុំបានអានខ្លះដែរ <ឃើញថាមានចំណុចល្អមួយចំនួន>។ ប៉ុន្តែចង់ដឹងថាតើក្រុមលោក តើលោកមានរកឃើញអ្វីដែលសំខាន់ដែលអាចបំភ្លឺបានទៅលើបញ្ហាអីនោះទេ?

[១០:១០:00]

**លោក វ៉ិចទ័រ កូប៉េ៖**

កត្តាមួយសំខាន់ដែលធ្វើឲ្យយើងមានបញ្ហាបំផុតនោះ <>គឺការពឹងផ្អែក<ទាំងស្រុង>ទៅលើរបាយការណ៍ជីកគាស់ផ្នូរ<>របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលឯកសារនេះត្រូវពង្រាងដោយក្រេក អេតឆេសាន់។ ហើយ អេវើលីន ក៏ពឹងផ្អែកផងដែរទៅលើទិន្នន័យរបស់គាត់នេះ។ <ប្រសិនបើ> យើង<អាច>រកឃើញនូវកំហុសជាមូលដ្ឋាន<> នៅក្នុង<ការ>ស្រាវជ្រាវ<ជីកគាស់ផ្នូរទាំងអស់> នេះ <វាគួរឲ្យចាប់អារម្មណ៍ខ្លាំងណាស់ បើគាត់អាចធ្វើអ៊ីចឹងមែននោះ។ ដោយ>ទទួល<ស្គាល់>នូវ<សក្តានុពលនៃ>កត្តាថ្មី<ៗទាំងអស់>នេះ <ថាតើគាត់>គួរ<យល់ស្របជាមួយយើងទេថា> ចំនួនហ្នឹងគួរតែតិច គួរតែទាបជាងនេះ។ អ្វីដែលសំខាន់បំផុត គឺគាត់ហាក់ដូចជាមិនបាននិយាយអំពីការស្លាប់ដែលកើតឡើងក្នុងចន្លោះ៧៥-៧៩នោះឡើយ គឺគាត់និយាយអំពីការស្លាប់ពីឆ្នាំ៧០ ដល់ ៧៩ ព្រោះថា <នេះជា>រយៈពេល<ពាក់ព័ន្ធ> ដែល<គេ>អាច<ឈានទៅដល់ការធ្វើសេចក្តីសន្និដ្ឋានបាន។ ក្នុងន័យនេះ វាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់>យើង<ដើម្បី>មាន<លទ្ធភាព>ពិភាក្សាជាសាធារណៈអំពី<ផលប៉ះពាល់នៃ>ការទម្លាក់គ្រាប់បែករបស់អាមេរិកទៅលើប្រទេសកម្ពុជានៅចន្លោះពីឆ្នាំ<៦៧> ដល់៧៣ ក៏ដូចជាសង្គ្រាមស៊ីវិល។ គឺមានបញ្ហាជាច្រើនដែលយើងខ្ញុំជឿជាក់ថាវាជាបញ្ហាសំខាន់ដែលយើងអាចជជែកជាមួយគាត់បាន។

ខ្ញុំយល់ថា សម្រាប់ការសម្រេចទៅលើអង្គច្បាប់គឺវាមិនខុសគ្នាអីនោះទេ ទោះបីថាមនុស្ស

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

៨០០.០០០ ឬក៏ ៥០០.០០០ ឬក៏តែ១០០.០០០នាក់ ស្លាប់ដោយសារអំពើហិង្សា<ក៏ដោយ។> ប៉ុន្តែ<ការតវ៉ាដូចគ្នានេះគឺ>ចំពោះ<ចំនួន>មនុស្សដែលត្រូវបានគេឃុំខ្លួន ហើយនិងសម្លាប់នៅស-២១<>។ ដូច្នេះប្រហែលជាសួរថាហេតុអី<បានជាមិនចង់ឲ្យមានសវនាការបែបនេះ? នេះជាអ្វីដែលតែងតែលេចឡើងមក។ នេះជាបញ្ហាដំបូងដែលគេឃើញ> នៅពេលដែលយើងធ្វើការស្រាវជ្រាវតាម*ហ្គូហ្គល* គឺយើងឃើញមនុស្សនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យស្លាប់ប្រហែលជា ១,៨លាន ទៅ ២លានជាដើម។ ដូច្នេះ ខ្ញុំគិតថាប្រជាជនកម្ពុជា ក៏ដូចជាសហគមន៍អន្តរជាតិទាំងមូល គួរតែទទួលបាននូវការពិភាក្សាមួយដែលច្បាស់លាស់។

[១០:១២:៤៤]

<បើទោះជានៅពេលចុងក្រោយ វានាំទៅដល់ការសន្និដ្ឋានផ្លូវច្បាប់ដែលយើងស្វែងរកឬក៏យ៉ាងណាក៏ដោយ> ខ្ញុំយល់ ហេតុអ្វីបានលោកស្រីចៅក្រមនិយាយបែបនេះ ប៉ុន្តែ<តើវាមានន័យថា>យើង<មិន>គួរពិភាក្សា<ពីបញ្ហានេះទេឬ>? <>ទេ។ <ខ្ញុំគិតថា វាជាប្រធានបទមួយ>សំខាន់<ណាស់។> វាទាក់ទងផ្ទាល់ថាតើពិភពលោកយល់ឃើញយ៉ាងម៉េច មើលឃើញយ៉ាងម៉េច អំពីរបបកម្ពុជាប្រជាធិបតេយ្យ។ ប្រសិបបើ<>ចំនួន<>ទាបជាងអ្វីដែលអ្នកជំនាញបាននិយាយកន្លងមក វាជារឿងសំខាន់សម្រាប់ នួន ជា ហើយក៏សម្រាប់ ខៀវ សំផន ផងដែរ។ ដែលថាៗកម្ពុជាប្រជាធិបតេយ្យគួរតែមើលឃើញក្នុងលក្ខណៈមួយផ្សេង បើធៀបជាមួយនឹងតណ្ហនេស៊ីក្នុងឆ្នាំ៦៥ ជាដើមនោះ។ ខ្ញុំគិតថាសម្រាប់បញ្ហាប្រវត្តិសាស្ត្រ សម្រាប់បញ្ហាអង្គហេតុ ក៏ដូចជាសម្រាប់កូនក្តីខ្ញុំផងដែរ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំគិតថានេះជាការបញ្ជាក់លម្អិត ច្បាស់លាស់ ហើយអង្គជំនុំជម្រះក៏ចង់ស្តាប់អំពីបញ្ហាប្រវត្តិសាស្ត្រដែរ ប៉ុន្តែដូចដែលខ្ញុំបញ្ជាក់អីចឹង គឺថាចំពោះបញ្ហាអង្គហេតុមួយចំនួនដែលមិនមានសារៈសំខាន់ចំពោះអង្គច្បាប់ដែលយើងត្រូវបញ្ជាក់បំភ្លឺនៅក្នុងសវនាការនេះ ប្រសិនបើយើងត្រូវការនោះ ប្រហែលជាត្រូវការដល់រាប់ទសវត្សរ៍ឯណោះ ដើម្បីកោះហៅអ្នកប្រវត្តិសាស្ត្រ អ្នកជំនាញអីផ្សេងៗ។ ខ្ញុំគិតថាអ្វីដែលយើងចង់និយាយជាសាធារណៈនៅពេលនេះ គឺអំពីទិន្នន័យ។ គឺថាវាជាទិន្នន័យមួយពីឆ្នាំ៦២ មួយទៀតពីឆ្នាំ៩៨។ <នៅចន្លោះនោះមានសង្គ្រាមស៊ីវិល មាន>របបកម្ពុជាប្រជាធិបតេយ្យ (របបខ្មែរក្រហម) ហើយនិងការចូលមកកាន់កាប់របស់វៀតណាម គឺប្រាកដណាស់ថាវាមានរឿងហេតុជាច្រើនកើតឡើង ហើយដោយសារតែមិនមានៗទិដ្ឋភាពមួយដែលច្បាស់លាស់ជាងនេះ។ ខ្ញុំយល់អំពីទឡ្ហីករណ៍

របស់លោកសូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក។

[១០:១៥:២៧]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បាទ ខ្ញុំមានសំណួរមួយចោទសួរទៅមេធាវី នួន ជា។ លោកមេធាវី នួន ជា បាននិយាយអំពីការដែលគាត់បានសុំទៅឲ្យសហចៅក្រមស៊ើបអង្កេត ដើម្បីឲ្យចាត់កោះហៅអ្នកជំនាញម្នាក់ទៀត គឺក្រៅពីអ្នកដែលបានកោះហៅ <ហើយនោះជាសំណើលើកទី>២៦ <ដែលត្រូវបានបដិសេធដោយ>សហចៅក្រមស៊ើបអង្កេត<>។ អ៊ីចឹងខ្ញុំៗចង់ដឹងថា តើ<>ដីកា<ហ្នឹង>បដិសេធ<ការតែងតាំងអ្នកជំនាញប្រជាសាស្ត្រថ្មី> ដែលមានប្ដឹងឧទ្ធរណ៍ទេ ប្ដឹងសាទុក្ខទេ?

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមិនច្បាស់ទេ ប៉ុន្តែខ្ញុំគិតថាយើងមិនបានធ្វើទេ ខ្ញុំប្រហែលជាត្រូវពិនិត្យមើលឡើងវិញ។ ប៉ុន្តែមានសំណើប្រហាក់ប្រហែលគ្នាមកពីខាង អៀង សារី ដែលស្នើសុំឲ្យកោះហៅ ឲ្យមានការចាត់តាំងអ្នកជំនាញមួយរូបផ្សេង ពួកគាត់បានប្ដឹងឧទ្ធរណ៍ទៅអង្គបុរេ ប៉ុន្តែអ្វីដែលយើងទទួលបាន គឺៗការសម្រេចទៅលើនីតិវិធី មិនមែនសម្រេចទៅលើអង្គសេចក្ដីនោះទេ។ យើងបានប្ដឹងឧទ្ធរណ៍ទៅលើសេចក្ដីសម្រេចមួយក្នុងឆ្នាំ២០១០ ប៉ុន្តែឥឡូវនេះ ខ្ញុំមិនអាចឆ្លើយទៅនឹងសំណួររបស់លោកចៅក្រមបានឡើយ ប៉ុន្តែខ្ញុំគិតថា បន្តិចទៀតខ្ញុំនឹងជម្រាបជូនលោកចៅក្រមបាន។

[១០:១៧:០៣]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ទី២ គឺជាការកត់សម្គាល់ទេ មិនមែនជាសំណួរទេ។ គឺបើខ្ញុំស្ដាប់លោកនិយាយតាមរយៈការបកប្រែអំមិញហ្នឹងបានច្បាស់ហ្នឹង គឺលោកមេធាវីបាននិយាយថា អង្គជំនុំជម្រះបានសម្រេចនៅក្នុងសាលក្រមរបស់ខ្លួននៅក្នុងសំណុំរឿង០០២/១ ដោយរក្សានូវចំនួនអ្នកស្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យហ្នឹង <ហើយខ្ញុំជឿថា>នៅកថាខណ្ឌ១៧៤ <នៃការសម្រេចនោះ គឺជាកថាខណ្ឌដែលលោកនិយាយយោងនោះ>។ ខ្ញុំអានកថាខណ្ឌនេះ<ឡើងវិញ ហើយ>អង្គជំនុំជម្រះបានយោងទៅនឹងតួលេខមួយចំនួនដែលផ្ដល់ឲ្យដោយអ្នកជំនាញ គឺអង្គជំនុំជម្រះមិនបានចេញសេចក្ដីសម្រេចអីទេ គឺយោងទៅនឹងតួលេខ

ដែលអ្នកជំនាញបានផ្តល់ឲ្យតែប៉ុណ្ណឹងទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

យើងមិនយល់ស្របទេលោកចៅក្រមឡាវែន៍។ ដូចដែលយើងបានបញ្ជាក់នៅក្នុងសារណាបណ្តឹងសាទុក្ខរបស់យើង គឺយើងបានលើកឡើងថា កថាខណ្ឌ១៧៤ ក្នុងសាលក្រម គឺជាការសម្រេចទៅលើអង្គហេតុ ដែលថា ដែលនិយាយអំពីចំនួននៃការស្លាប់ដ៏ច្រើនលើសលប់ពីចន្លោះ ១,៥លាន ទៅ ២លាន នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ព្រោះថា យើងបានលើកនូវទឡ្ហីករណ៍ ហើយខ្ញុំសូមដកស្រង់៖ "តាំងពីអង្គជំនុំ -- ដោយសារអង្គជំនុំជម្រះបានបញ្ជាក់ច្បាស់លាស់រួចមកហើយថា អ្នកជំនាញបានទទួលស្គាល់នូវភាពត្រឹមត្រូវនៃចំនួនមនុស្សស្លាប់នេះ។ ហើយខ្ញុំនឹង -- ហើយមិនយោងទៅលើចំណុចណាមួយទៀតដែលមានការជំទាស់ផ្សេងនៅក្នុងសាលក្រមនោះឡើយ។

ដោយការបញ្ជាក់យ៉ាងច្បាស់ថា "អ្នកជំនាញបានទទួលស្គាល់" យើងខ្ញុំប្តឹងសាទុក្ខថានេះជាការសម្រេចទៅលើអង្គហេតុដែលវាជា -- ដែលនាំទៅដល់កំហុសអង្គច្បាប់។ <ថាតើយើងយល់ស្រប ឬមិនយល់ស្រប> ប្រាកដណាស់ថា <>គឺថានៅពេលនេះវាមិនសំខាន់នៅពេលនេះឡើយ វាអាស្រ័យទៅលើអង្គជំនុំជម្រះតុលាការកំពូលថា សម្រេចយ៉ាងណានោះ។

[១០:១៩:២៥]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ប៉ុន្តែអ្វីដែលសំខាន់នោះគឺថា យើង<ពិនិត្យមើលលើ>អង្គហេតុ ហើយនិងចេញសេចក្តីសម្រេចឲ្យត្រឹមត្រូវ។ <នៅពេលដែលយើងនិយាយថា អ្នកជំនាញទទួលស្គាល់តួលេខនេះ វាមិនមានន័យថា> អង្គជំនុំជម្រះទទួល<ស្គាល់តួលេខនោះទេ>។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំអានមួយសាទៀតបាន ប៉ុន្តែយើងមិនយល់ស្របជាមួយនឹងអ្វីដែលបានសរសេរនោះទេ។ ក្នុង<>អង្គហេតុដែលថា <>មិនមានការពិភាក្សា<អំពីរឿងនេះ ហើយ>មិនមានការយោងទៅលើទឡ្ហីករណ៍កន្លងមករបស់យើងនោះ ដោយសារហេតុផលនេះហើយទើបយើងបកស្រាយថា កថាខណ្ឌ១៧៤ ហ្នឹងគឺជាការសម្រេចទៅលើអង្គហេតុ ដែលនាំទៅដល់កំហុសលើអង្គច្បាប់ដែលយើងធ្វើការប្តឹងសាទុក្ខ។ ប្រសិនបើយើងយល់ឃើញខុសយ៉ាងណានោះ ខ្ញុំប្រាកដណាស់ថាតុលាការកំពូលនឹងច្រានចោលនូវបណ្តឹងសាទុក្ខរបស់យើងត្រង់ចំណុចនេះ។ នេះគឺជាអ្វីដែលយើងបកស្រាយកថាខណ្ឌ១៧៤។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១០:២០:៤០]

ហើយខ្ញុំសូមបន្ថែមផងដែរថា ក្នុងពេលថ្មីនេះខ្ញុំបានដឹងអំពីការសម្ភាសមួយដែលចៅក្រម ហ្វេនស៍ បានផ្តល់ទៅឲ្យនៅថ្ងៃ១៥ មករា ២០១០ អំពី -- ខ្ញុំគិតថាវាជាទស្សនៈផ្ទាល់ខ្លួនរបស់ចៅក្រម ហ្វេនស៍ ដែលនិយាយអំពីចំនួន<ដ៏>ច្រើនលើសលប់នៃអ្នកស្លាប់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យគឺមួយចុចប្រាំបី ។ <សម្រាប់ខ្ញុំវាហាក់ដូចជា>ថា <>នេះជាទស្សនៈរបស់អង្គជំនុំជម្រះទាំងមូល<>។ ខ្ញុំអាចអាន<> ជាភាសាអាល្លឺម៉ង់បាន។ <ចៅក្រម ហ្វេនស៍ និយាយថា> "ហេតុអ្វីបានជាមនុស្ស១,៨លាននាក់ បានស្លាប់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ? ព្រោះថាដោយសារ<>មានចំនួនមនុស្សស្លាប់ដល់ ១,៨លាននាក់នោះ <ទើបមានចារីច្រើនដែរ>។ <ដូច្នេះមិនមានគុណវុឌ្ឍិពិតប្រាកដទេ យោងតាមចៅក្រមនៅក្នុងអង្គជំនុំជម្រះនេះ ហើយ>ខ្ញុំគិតថាវា<គឺជាទស្សនៈផ្ទាល់ខ្លួន> ដែល<ថា>ចំនួនស្លាប់ ១,៨លាន<នាក់ដោយអំពើហិង្សានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ>។ ដូច្នេះ<នេះជាអ្វីដែលយើងអាចអាននៅក្នុងកថាខណ្ឌ១៧៤ ហើយប្រាកដណាស់ថា វាស្រេចតែអង្គជំនុំជម្រះតុលាការកំពូលជាអ្នកសម្រេចតែប៉ុណ្ណោះ។ ប៉ុន្តែសម្រាប់យើង គឺវាច្បាស់ណាស់។>

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ចៅក្រម ហ្វេនស៍ គាត់បានចេញសាលដីកានៅសំណុំរឿង <០០២/០១>។

**លោក វ៉ិចទ័រ កូប៉េ៖**

ពិតណាស់ យ៉ាងណាក្តីតែប៉ុណ្ណឹងឯង។

[១០:២២:៤០]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំតែងតែប្រុងប្រយ័ត្នក្នុងការផ្តល់សម្ភាសន៍ ប៉ុន្តែខ្ញុំមិនចាំអំពីការសម្ភាសនេះទេ <ដោយសារ> វា<>កើតឡើង៦ឆ្នាំ<ហើយ>។

**លោក វ៉ិចទ័រ កូប៉េ៖**

<តើ>ខ្ញុំអាចអាន<ជូនលោកស្រីស្តាប់>បាន<ទេ?>

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

មិនបាច់ទេ មិនបាច់អានទេ។ ប៉ុន្តែដោយសារតែបានបញ្ជាក់ថា ដើម្បីបញ្ជាក់ច្បាស់អំពីចម្លើយរបស់យើងចំពោះអនុស្សរណៈ។ ដូច្នេះ លោកមិន<>ស្នើសុំ<ស្តាប់សក្ខីកម្ម អ៊ីវ៉ា> តាបូ <ទេ ប៉ុន្តែ

លោកស្នើសុំឲ្យចាត់តាំង> អេវើលីន <ជាអ្នកជំនាញ ហើយអង្គហេតុដែលលោកត្រូវរកឲ្យឃើញនោះគឺចំនួនអ្នកស្លាប់ទូទៅនោះមានច្រើនលើសលប់ពេក>។ <ជាទូទៅ គឺផ្ទុយទៅនឹងចំនួនជនជាតិភាគតិចដែលស្លាប់ច្រើនលើសលប់> ព្រោះថា<ប្រាកដណាស់ គាត់មិននិយាយអ្វីពីបញ្ហានោះទេ>។ តើខ្ញុំយល់អីចឹងត្រឹមត្រូវទេ?

**លោក វ៉ិចទ័រ កូប៉េះ**

ដើម្បីច្បាស់ហើយនិងឲ្យត្រឹមត្រូវជាក់ស្តែងនោះ អ្វីដែលគួរស៊ើបអង្កេត គឺនៅក្នុងសំណើសុំទី៥ គឺសំណើសុំបំពេញកិច្ចស៊ើបសួររបស់យើងខ្ញុំ ទី៥ ទី៦។ ហើយនិងបណ្តឹងសាទុក្ខរបស់យើងខ្ញុំប្រឆាំងទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ។ <>ឯកសារទាំង<បី>នេះរួមគ្នា គឺជា<>អ្វីដែលកំណត់ដោយអ្នកជំនាញប្រជាសាស្ត្រ។ ដូច្នេះ ខ្ញុំគិតថាអ្នកជំនាញប្រជាសាស្ត្រមិនគួរគិតតែទៅលើចំនួនស្លាប់របស់ជនជាតិចាម ជនជាតិវៀតណាមអីនោះទេ ប៉ុន្តែគួរតែស្រាវជ្រាវឲ្យឃើញអំពីចំនួនស្លាប់របស់អ្នកស្លាប់ដោយផ្ទាល់ និងដោយប្រយោលនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ នៅមុន<កម្ពុជាប្រជាធិប-តេយ្យ> និងនៅក្រោយ<កម្ពុជាប្រជាធិបតេយ្យ>។

[១០:២៤:២៨]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ប៉ុន្តែខ្ញុំគិតថា<គាត់មិនបាននិយាយពី>ចំនួនអ្នកស្លាប់របស់ចាមនិងវៀតណាម<ទេ ឬក៏ប្រហែលជាខ្ញុំអានលើសអ្វីមួយហើយ>?

**លោក វ៉ិចទ័រ កូប៉េះ**

<ទេ មិនមាននៅក្នុងការបោះពុម្ព>ចុងក្រោយ<របស់គាត់នៅ>ឆ្នាំ២០១៥<ទេ> ប៉ុន្តែគាត់បោះពុម្ពអត្ថបទជាច្រើននៅក្នុងឆ្នាំ៩៨ ផងដែរ។ ហើយអត្ថបទរបស់គាត់ត្រូវបានគេប្រើប្រាស់យ៉ាងច្រើន។ មិនមែនត្រឹមតែឆ្នាំ២០១៥មួយនោះទេ។ ខ្ញុំកំពុងតែពិនិត្យមើលចំណងជើងឲ្យច្បាស់ប្រាកដ ប៉ុន្តែ<វាប្រហែលជាមាន>នៅក្នុងជើងទំព័ររបស់លោកស្រីផងដែរ គឺប្រាកដណាស់ថាមាននៅក្នុងជើងទំព័រ ៥២៣ នៅក្នុងសាលក្រម <ដែល>និយាយយោងទៅលើ <អេវើលីន ដែលថាមាន>ចន្លោះពី ១ ទៅ ៣ លាន នៅក្នុងប្រវត្តិសាស្ត្រនៃកម្ពុជា គឺ ឯកសារ E3/1799 ពីឆ្នាំ៩៨។ ខ្ញុំមិនមានឯកសារនេះនៅពេលនេះទេ ប៉ុន្តែគាត់យោងអំពីការស្រាវជ្រាវ<ផ្សេងៗទៀត រួមទាំង> វីកឃើរី ផងដែរ។ ដូច្នេះ<នៅក្នុងការបោះពុម្ពផ្សាយរបស់គាត់នៅ>ក្នុងឆ្នាំ៩៨ <ជាមួយនឹង>ការបោះពុម្ពផ្សាយឆ្នាំ<>២០១៥នេះ <ខ្ញុំ

ជឿថា វាគួរតែជាមូលដ្ឋានក្នុងការ>កោះហៅគាត់មកក្នុងនាមជាអ្នកជំនាញ។ យើងបានពិនិត្យមើលទៅលើប្រវត្តិរូបសង្ខេបរបស់គាត់រួចហើយ ហើយខ្ញុំមិនប្រាកដថាវាត្រឹមត្រូវ ឬក៏អត់នោះទេ ប៉ុន្តែជំនាញរបស់គាត់នៅក្នុងផ្នែកប្រជាសាស្ត្រ គឺវាច្រើនជាង 2-TCE-93។ មិនមែនត្រឹមតែក្នុងលក្ខណៈទូទៅនោះទេ ប៉ុន្តែសូម្បីចំណេះដឹងរបស់គាត់អំពីកម្ពុជា និងរបបកម្ពុជាប្រជាធិបតេយ្យ ក៏វាច្រើនលើសដែរ។

[១០:២៧:០៣]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ មានការកត់សម្គាល់និងការឆ្លើយតបមួយចំនួន។ ទី១ <ខ្ញុំគិតថាវាសំខាន់ ជាពិសេស>ដើម្បីឲ្យសាធារណជនយល់ថា ហេតុអ្វីបានជាចំនួនមនុស្សស្លាប់សរុបនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យថា វាជារឿងប្រវត្តិសាស្ត្រមួយដ៏មានសារៈសំខាន់ ហើយក៏វាមានបញ្ហាសំខាន់សម្រាប់ផ្នែកគតិយុត្តិនោះផងដែរ។ មិនមែនយើងត្រូវនិយាយអំពីកេរដំណែលបន្សល់ពីរបបនោះ ឬក៏យ៉ាងណានោះទេ។ <ខ្ញុំរីករាយចង់ឲ្យមានសវនាការបែបនេះជាមួយមេធាវីការពារក្តីនៅផ្ទះមេតា-ហៅស៍។> នេះគឺជាកិច្ចដំណើរការនីតិវិធីតាមផ្លូវច្បាប់ <ហើយហេតុផលដែល>អង្គជំនុំជម្រះ<> ពិភាក្សាទៅលើកថាខណ្ឌ១៧៤ នៃសាលក្រម<ពីមុនមកនោះ គឺងាយស្រួលសម្រាប់គោលបំណងនៃ> ធាតុផ្សំនៃ*អាទ្យ៉ូ*នេះ <ថាតើមាន ឬក៏មិនមានការរីករាលដាល និងការវាយប្រហារជាប្រព័ន្ធប្រឆាំងទៅនឹងជនស៊ីវិល>នៅក្នុងរបបនោះ<>។ ហេតុនេះជាហេតុផល<ដែល>បញ្ហានេះ<ត្រូវបានយកមកពិភាក្សា>។ ហើយវាជាបញ្ហាតែមួយគត់ គឺចំនួនអ្នកដែលស្លាប់សរុបនោះ គឺវាអាច<>មានការពាក់ព័ន្ធ<>។

ខ្ញុំមិនចង់ធ្វើការជំទាស់ ពាក់ព័ន្ធទៅនឹងបណ្តឹងឧទ្ធរណ៍<នោះទេ។ ខ្ញុំគិត>ថា ទោះពីចំណុចណាមួយក៏ដោយ គឺថាមិនអាចឈានទៅដល់សេចក្តីសន្និដ្ឋាន<ណាផ្សេងទៀត ក្រៅ>ពី<>ថា<>មានការ<រីករាលដាល និងការ>វាយប្រហារជា<ប្រព័ន្ធ>មកលើជនស៊ីវិល <ហើយគ្មាន>មធ្យោបាយណាមួយដែលៗអាចឲ្យរកឃើញថា <>ចំនួនអ្នកស្លាប់ពិតប្រាកដនៃរបបនោះ មានចំនួនពិតប្រាកដប៉ុន្មាននោះទេ គ្រាន់តែថា វាជាចំណុចមួយយើងត្រូវដឹងថា វិសាលភាពនៃការស្លាប់នេះ វាក្នុងកម្រិតណា តែត្រង់ថាតួលេខឲ្យច្បាស់លាស់សុក្រិតតែម្តងនោះ គឺថាមិនអាចទេ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១០:២៩:១៤]

យើងឃើញថា មានភស្តុតាងចម្រូងចម្រាសគ្នា ពាក់ព័ន្ធទៅនឹងបញ្ហាមន្ទីរសន្តិសុខ ដែលត្រូវបានបង្កើតនៅគ្រប់ស្រុក តំបន់ ភូមិភាគទាំងអស់<ក្នុងប្រទេសនេះ> ហើយប្រជាជនត្រូវបានគេ<ចាប់ខ្លួន> និងសម្លាប់ចោល ដោយអត់មានជំនុំជម្រះតាមផ្លូវច្បាប់ណានោះឡើយ។ ហើយមជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើការកំណត់ផែនទី ទីតាំង<សម្លាប់មនុស្ស និង>មន្ទីរសន្តិសុខនៅទូទាំងផ្ទៃប្រទេស ហើយ<សក្ខីកម្ម និង>ចំនួន<ជនរងគ្រោះនៅទូទាំងប្រទេស> គឺថាវាមានចំនួនប្រហាក់ប្រហែល។ មានភស្តុតាងរាប់រយពាន់ភស្តុតាង ដែលថាហេតុអ្វីបានជាមាន<រីករាលដាល និង>ការវាយប្រហារ<ជាប្រព័ន្ធ>មកលើជនស៊ីវិលនោះ។ <ប៉ុន្តែវាសំខាន់ក្នុងការ>យល់<ថា> នេះ<ជា>សេចក្តីសន្និដ្ឋាន<តែមួយគត់ ឬជាសាលក្រម>ដែលអង្គជំនុំជម្រះ<ត្រូវ>សម្រេចនៅត្រង់ចំណុចនេះ<>។ ខ្ញុំមិនយល់ស្របទៅនឹងការកំណត់ចរិតលក្ខណៈដែលបានយល់ឃើញនៅសាលក្រម ដូចបានលើកឡើងដោយមេធាវីក្តីនោះទេ។

ប្រសិនណាជាមេធាវីការពារក្តីចង់ស្នើសុំ<អ្នកជំនាញផ្សេងទៀត>នោះ ខ្ញុំថាគួរតែដាក់សំណើ។ <ពេលដែលខ្ញុំអង្គុយនៅទីនេះ ខ្ញុំមិនបានត្រៀមខ្លួនទៅ>ពិនិត្យមើល<ការងារពីមុនៗមករបស់ ប៉ាទ្រីក អេវើលីន នោះទេ ថាតើគាត់បាន>ធ្វើការវិភាគទៅលើ<>ចំនួនជនជាតិចាម វៀតណាម ដែលស្លាប់ដែរឬយ៉ាងណានោះ។ <ខ្ញុំគិតថា លោកចៅក្រមយល់ត្រឹមត្រូវទៅលើបញ្ហា>នេះ គឺ<ថា បើយើងមាននរណាម្នាក់ដែលបានធ្វើការស្រាវជ្រាវទៅលើបញ្ហានោះ នោះវា>ជាបញ្ហាមួយផ្សេងទៀត។<ពិតណាស់ខ្ញុំគិតថា>យើងខ្ញុំទាំងពីរយល់ស្របថា ប៉ែន យៀរនិន បើសិនណាជាមានពេលគឺថា គាត់អាចមកឆ្លើយបាន។ <ដូច្នេះហើយ ពេលដែលខ្ញុំនៅក្នុងសវនាការនេះ ខ្ញុំមិនបានត្រៀមដើម្បីដឹងថាតើ ប៉ាទ្រីក អេវើលីន បានស្រាវជ្រាវលើបញ្ហានេះដែរឬទេ។> បើសិនណាជាមេធាវីការពារក្តីចង់ឲ្យកោះហៅ គឺថាយើងខ្ញុំនឹងចាំរង់ចាំពិនិត្យមើលថាតើសំណើសុំនោះវាយ៉ាងណា។

**ប្រធានអង្គជំនុំ៖**

អរគុណលោកព្រះរាជអាជ្ញា។

លោកស្រីមេធាវីដើមបណ្តឹងរដ្ឋប្បវេណី តើលោកមានយោបល់ទេលើបញ្ហានេះ?

[១០:៣១:២២]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងខ្សែបកប្រែ និងខ្សែបកប្រែបន្ត។*

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានការកត់សម្គាល់ខ្លីមួយពាក់ព័ន្ធនឹងចំណុចនេះ។ យើងគោរពតាមការសម្រេចរបស់អង្គជំនុំជម្រះពាក់ព័ន្ធនឹងការពិភាក្សាគ្នាទៅលើ អេវ៉ា តាបូ ក៏ប៉ុន្តែអ្វីដែលបានលើកឡើងថ្មីៗនេះ<នៅក្នុងសវនាការសាធារណៈ> នាំឲ្យខ្ញុំធ្វើការកត់សម្គាល់ខ្លីមួយ ដើម្បីឲ្យអង្គជំនុំជម្រះជ្រាបច្បាស់អំពីគោលជំហររបស់យើង និងដើម្បីឲ្យសាធារណជនយល់អំពីគោលជំហររបស់ដើមបណ្តឹងរដ្ឋប្បវេណី។

យើងបានយល់ដូចដែលចៅក្រម ហ្វេនស៍ បានលើកឡើងជាច្រើនដងហើយថា ចំនួនជនរងគ្រោះជាបញ្ហាប្រវត្តិសាស្ត្រដ៏សំខាន់ ហើយវាមិនមានឥទ្ធិពលអ្វីទៅលើការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ នួន ជា និង ខៀវ សំផន ទេ។ ចំនួនជនរងគ្រោះហ្នឹងគឺវាមិនពាក់ព័ន្ធទៅនឹងបញ្ហាឧក្រិដ្ឋកម្ម<ប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្ម>សង្គ្រាម ឬក៏ប្រល័យពូជសាសន៍ដែលកាត់ទោស នួន ជា និង ខៀវ សំផន ទេ។ ចំនួនជនរងគ្រោះនៅក្នុងអំពើប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិវៀតណាមនិងចាម ក៏វាមិនមានភាពពាក់ព័ន្ធ ដើម្បីឲ្យអង្គជំនុំជម្រះសម្រេចទៅលើការកំណត់ប្រភេទនៃបទល្មើសនៃអំពើប្រល័យពូជសាសន៍នោះដែរ។ ខ្ញុំយល់អំពីការអះអាងរបស់មេធាវី នួន ជា ថាចំនួនស្លាប់សរុបនោះគឺជារឿងសំខាន់សម្រាប់ការការពារក្តី ក៏ប៉ុន្តែ<វាគ្មានតម្លៃអ្វីទាំងអស់ តាមផ្លូវច្បាប់។ យ៉ាងណាក៏ដោយ យើងកំពុងតែនិយាយគ្នាពី>ការជំនុំជម្រះក្តី <ហើយ>យើង<កំពុងតែ>ចូលរួម<ក្នុងការជំនុំជម្រះនេះ>ទាំងអស់គ្នា។ ហើយតាមផ្លូវច្បាប់ បញ្ហានេះគឺមិនមានឥទ្ធិពលអ្វីទេ។ ដូច្នេះខ្ញុំសូមឲ្យអង្គជំនុំជម្រះពិចារណាទៅលើបញ្ហាជាមូលដ្ឋាននេះ ហើយនិងថ្លឹងថ្លែងជាមួយនឹងផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីធ្វើយ៉ាងណាឲ្យការជំនុំជម្រះក្តីនេះបញ្ចប់ទៅដោយឆាប់រហ័ស។ ពាក់ព័ន្ធនឹងសំណើរបស់មេធាវីការពារក្តីនៅថ្ងៃនេះ ក្នុងការសុំឲ្យកោះហៅសាស្ត្រាចារ្យ ប៉ាទ្រីក អេវើលីន បើខ្ញុំយល់អំពីតួលេខនៃចំនួនមនុស្សស្លាប់ គឺជាពិសេសជនជាតិវៀតណាម និងចាមនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ វាមិនមានឥទ្ធិពលអ្វីទៅលើការកំណត់ប្រភេទ បទល្មើសជាអំពើប្រល័យពូជសាសន៍នោះទេ។

*(ចៅក្រមពិភាក្សាគ្នា)*

[១០:៣៤:២៣]

**ប្រធានអង្គជំនុំ៖**

លោកមេធាវីការពារលោក ខៀវ សំផន តើលោកមានយោបល់យ៉ាងណាដែរចំពោះបញ្ហានេះ?

**កញ្ញា អង់តា ហ្គីសសេះ**

សូមអរគុណលោកប្រធាន។ លោកប្រធាន ខ្ញុំសូមលើកឡើងដោយខ្លី។ ទី១ គឺពាក់ព័ន្ធនឹងបញ្ហាសំខាន់ដែលថាយើងគាំទ្រក្នុងការស្នើសុំកោះហៅ 2-TCE-93។ នៅក្នុងសារណា <E305/9> គឺយើងបានបញ្ជាក់ច្បាស់ហើយ ថាគាត់មិនមានឋានៈជាអ្នកជំនាញទេ ដោយសារតែវិធីសាស្ត្ររបស់គាត់ និង <មាតិកានៃការងាររបស់គាត់>មានភាពលម្អៀង។ <>នៅថ្ងៃនេះគឺយើង<មិនអាច>លើកឡើងផ្ទុយទៅវិញ<ទេ>។ <បញ្ហាពិតដែលជាកង្វល់នៃការពិភាក្សារបស់យើង>នៅថ្ងៃនេះ យើងមិន<ចង់>ដឹងថា<តើ>គាត់មកផ្តល់សក្ខីកម្ម<ឬក៏អត់>នោះទេ <ដោយសារខ្ញុំយល់ថា បើខ្ញុំអានខ្លឹមសារនៃសារដែលគាត់ផ្ញើមកអង្គជំនុំជម្រះ ដោយផ្តល់នូវ>លក្ខខណ្ឌបច្ចុប្បន្ននោះ ប្រហែលជាគាត់មិនមកផ្តល់សក្ខីកម្មទេ។ <សំណួរពិតគឺយើងធ្វើអ្វីជាមួយនឹង>របាយការណ៍របស់គាត់ គឺឯកសារE3/2413។ <នេះជាសំណួរពិត។> បើគាត់មិនមកផ្តល់សក្ខីកម្មទេ ហើយយើងមិនអាចចោទសួរគាត់ទៅលើវិធីសាស្ត្រ និងប្រភពនៃការធ្វើការងាររបស់គាត់ទេ ដូច្នេះអង្គជំនុំជម្រះអាចពិចារណាទៅលើរបាយការណ៍គាត់ហ្នឹង មិនអាចយកមកធ្វើជាភស្តុតាងអ្វីបានធំដុំទេ។ ខ្ញុំដឹងហើយថា បើខ្ញុំយល់មិនច្រឡំទេ វិធីសាស្ត្រនៃការសរសេររបាយការណ៍របស់គាត់នោះ 2-TCE-93 ហ្នឹងគាត់បានប្រមូលទិន្នន័យដែលមានតែស្រាប់តែប៉ុណ្ណោះ ហើយគាត់ធ្វើការវិភាគ។ ដូច្នេះយើងនៅតែលើកឡើងនូវជំហររបស់យើងដដែលគឺយើងចង់ឲ្យមានការកោះហៅគាត់ ហើយបើគាត់មិនមកទេគឺឯកសាររបស់គាត់ហ្នឹងគឺមិនអាចមានតម្លៃជាភស្តុតាងអ្វីធំដុំបានទេ។

[១០:៣៦:៥៥]

ចំណុចមួយទៀតដែលខ្ញុំចង់លើកឡើងផងដែរ វាជាការស្មុគស្មាញណាស់ក្នុងនិយាយអំពីតួលេខនៅពេលដែលយើងនិយាយអំពីចំនួនមនុស្សស្លាប់នោះ ពីព្រោះថា គឺថាការចំនួនមនុស្សស្លាប់ហ្នឹងវាច្រើនពេក។ ហើយឥឡូវនេះគេនាំគ្នានិយាយថាចំនួនមនុស្សស្លាប់ ទោះបីជាស្លាប់ដោយអំពើហិង្សា ឬក៏ស្លាប់ដោយបញ្ហាអ្វីក៏ដោយមិនមានផលប៉ះពាល់អ្វីក្នុងរឿងព្រហ្មទណ្ឌនោះ វាមិនត្រឹមត្រូវទេ។ ហេតុអី? ពាក់ព័ន្ធនឹងការកំណត់ប្រភេទនៃបទល្មើសនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនោះ យើងត្រូវកំណត់ឲ្យបានច្បាស់ថាតើមានធាតុផ្សំអ្វីខ្លះ? ក៏ប៉ុន្តែខ្ញុំសូមរំឭកថា ពាក់ព័ន្ធនឹងការប្រកាសទោសទៅលើជនជាប់ចោទនោះ នៅពេលដែលអង្គជំនុំជម្រះធ្វើការផ្តន្ទាទោសនោះ សញ្ញាណនៃចេតនាដោយយោងទៅលើភាពខុសគ្នានៃការស្លាប់ដោយអំពើហិង្សា ឬក៏ស្លាប់ដោយសារលក្ខខណ្ឌជីវភាពនោះ វាពិតជាមានផលប៉ះពាល់ទៅលើ

ការពិភាក្សាគ្នាដែលនាំទៅសម្រេចទៅលើការកំណត់ប្រភេទនៃបទល្មើសនោះ នេះជាចំណុចសំខាន់។

បញ្ហាសំខាន់ដែលនឹងចោទឡើងនៅពេលដែលយើងនិយាយអំពីប្រជាសាស្ត្រ និងតួលេខនោះគឺវាមានបញ្ហា ដូចដែលមេធាវីការពារក្ដីបានលើកឡើងអម្បាញ់មិញនេះ ដោយគាត់បានលើកឡើងអំពីតួលេខដែលបានដាក់ -- ដែលបានលើកឡើងនៅក្នុងកថាខណ្ឌមួយចំនួនដែលមាននៅក្នុងសាលក្រមនៃសំណុំរឿង០០២/០១នោះ គឺតួលេខហ្នឹងវាមានផលប៉ះពាល់ហើយទៅលើការសម្រេចរបស់អង្គជំនុំជម្រះនោះ។ ច្បាស់ណាស់ថាមិនមែនរឿងសាមញ្ញទេ នៅពេលដែលយើងសួរដេញដោលសាក្សីនោះ តើនៅពេលដែលយើងសួរចង់ដឹងថាមានមនុស្សស្លាប់ប៉ុន្មានៗ ហើយមានអ្នកណាជាអ្នកចេញសេចក្ដីសម្រេច អ្នកណាជាអ្នកបញ្ជាឲ្យចាប់អីហ្នឹង គឺសុទ្ធតែមានផលប៉ះពាល់ហើយ។ ដូច្នេះ ខ្ញុំគិតថាបើមិនមានអ្នកជំនាញទៅលើ -- អ្នកជំនាញប្រជាសាស្ត្រមកផ្ដល់សក្ខីកម្មទេ គឺយើងមិនដឹងថាតើអង្គជំនុំជម្រះនឹងធ្វើយ៉ាងម៉េចចំពោះតួលេខដែលមានស្រាប់ ដែលខ្លួនមាននៅក្នុងរបាយការណ៍ផ្សេងៗនោះ។

**ប្រធានអង្គជំនុំ៖**

លោកស្រីមេធាវីសូមផ្អាកបន្តិចដោយសារ ឌីវីឌី អស់។ ឲ្យមន្ត្រីខាងសោតទស្សន៍ប្ដូរឌីវីឌីថ្មីរង់ចាំមួយនាទី។

[១០:៤០:០២]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីបន្ត សូមទោស លោកមេធាវីការពារលោក ខៀវ សំផន បន្ត។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។

ចំណុចមួយទៀតដែលខ្ញុំចង់លើកឡើងពាក់ព័ន្ធនឹងបញ្ហាប្រជាសាស្ត្រនោះ យើង ខ្ញុំគិតថាយើងនឹងមានអ្នកជំនាញនឹងមកផ្ដល់សក្ខីកម្មអំពីលក្ខខណ្ឌនៃការវិភាគទៅលើទីតាំងសម្លាប់មនុស្សមួយចំនួន។ ចំណុចទាំងអស់ហ្នឹងមានផលប៉ះពាល់ មានឥទ្ធិពល ពីព្រោះថាតាមផ្លូវច្បាប់វាជាភស្តុតាងសំខាន់ដែលត្រូវជជែកដេញដោលនៅក្នុងសវនាការនៅពេលដែលយើងរិះគន់ទៅលើវិធីសាស្ត្រដែលប្រើប្រាស់ក្រោយពីរបបកម្ពុជាប្រជាធិបតេយ្យផ្ដួលរលំនៅឆ្នាំ១៩៧៩ ដោយរដ្ឋអំណាចវៀតណាម ឬក៏ដោយអាជ្ញាធរថ្មីនៃកម្ពុជា។ យើងឃើញថាវាមានសារៈសំខាន់ ពីព្រោះថានៅពេលដែលយើងមានការជំនុំជម្រះក្ដី ដែលយូរណាស់មកហើយនៅក្នុងប្រទេសមួយដែលអង្គហេតុនុំងវាកើតឡើងរាប់ឆ្នាំមកហើយនោះ។ វាមាន

អង្គហេតុផ្សេងទៀតកើតឡើងក្រោយពីរបបនោះដួលរលំ គឺមានបន្តការវាយប្រយុទ្ធគ្នា ហើយឃើញថា នៅក្នុងរណ្ដៅសាកសពដែលមានសាកសពហ្នឹងក៏វាអាចមានការប្រែប្រួល ពីព្រោះថា យើងឃើញថា តាំងពីឆ្នាំចិត -- វាមានការប្រយុទ្ធគ្នានឹងតាំងពីឆ្នាំ៧០មក ហើយក្រោយឆ្នាំ៧៩ ក៏មានបន្តទៀត។ អ៊ីចឹង វាមិនប្រាកដថាអ្វីដែលយើងឃើញហ្នឹងវាកើតមានតែនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យទេ។

[១០:៤១:២៤]

អ្វីដែលយើងបានអាននៅក្នុងរបាយការណ៍របស់ 2-TCE-93 មិនអាចឲ្យអង្គជំនុំជម្រះផ្ដល់តម្លៃជាភស្តុតាងធំដុំបានទេ។ ក៏ប៉ុន្តែតួលេខនេះវាមានផលប្រយោជន៍ក្នុងការធ្វើសេចក្ដីសន្និដ្ឋានតាមផ្លូវច្បាប់ ហើយប្រសិនបើអង្គជំនុំជម្រះយកតួលេខទាំងអស់នេះមកធ្វើសេចក្ដីសន្និដ្ឋានទៅលើអង្គហេតុនោះ វាចោទជាបញ្ហា។ ទោះជាយ៉ាងណាក៏ដោយយើងត្រូវតែមានការប្រយ័ត្នប្រយែងខ្ពស់នៅពេលដែលយើងនិយាយអំពីតួលេខ ហើយប្រសិនបើមានការធ្វើកោសល្យវិច័យ ឬក៏មានអត្ថបទផ្សេងៗដែលយើងចង់ប្រើប្រាស់នៅចំពោះមុខអង្គជំនុំជម្រះនេះ យើងត្រូវតែពិនិត្យមើល ថាតើយើងមានលទ្ធភាពក្នុងការសួរដេញដោលតទល់ជាមួយនឹងអ្នកនិពន្ធទាំងអស់ហ្នឹង ដើម្បីឲ្យដឹងអំពីវិធីសាស្ត្រការងារ ហើយនិងអ្វីដែលគាត់បានស្រាវជ្រាវនោះ។

ដូច្នេះអង្គជំនុំជម្រះត្រូវតែគិតពិចារណាទៅលើចំណុចទាំងអស់ហ្នឹង ហើយមិនត្រូវប្រើប្រាស់តួលេខរបស់អ្នកនិពន្ធដោយចៃដន្យទេ។ យើងបានពន្យល់យ៉ាងច្បាស់ហើយថា ហេតុអ្វីបានជាតួលេខទាំងអស់ហ្នឹងត្រូវតែមានការពិភាក្សាដេញដោលគ្នានោះ ជំហររបស់យើងគឺនៅដដែល។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្វង់ម៉ាក!

[១០:៤៣:៥០]

**ចៅក្រម ហ្វង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ យើងយល់ហើយថា មេធាវីការពារក្ដីលោក ខៀវ សំផន មិនចង់ឲ្យអ្នកជំនាញ 2-TCE-93 មកផ្ដល់សក្ខីកម្មនោះទេ ក៏ប៉ុន្តែមេធាវីការពារក្ដីចង់ហៅអ្នកជំនាញផ្សេងទៀតមែនទេ? ខ្ញុំសារភាពថា ខ្ញុំមិនសូវយល់ពីអ្វីដែលលោកស្រីបានលើកឡើងអម្បាញ់មិញទេ។

**កញ្ញា អង់តា ហ្គីសសេ៖**

យើងអត់មានស្នើសុំអី កោះហៅអីទៀតទេ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

អ៊ីចឹងការធ្វើការកត់សម្គាល់ហ្នឹងគឺថា របាយកាណ៍នៅក្នុងសំណុំរឿងហ្នឹង គឺមានតម្លៃភស្តុតាងតិចតួចបំផុត បើអ្នកនិពន្ធហ្នឹងមិនបានមកផ្តល់សក្ខីកម្មមែនទេ?

**កញ្ញា អង់តា ហ្គីសសេ៖**

ពិតជាអ៊ីចឹងហើយលោកចៅក្រម។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវីការពារលោក នួន ជា!

[១០:៤៤:៤៤]

**លោក វ៉ិចទ័រ កូប៉េ៖**

មានបញ្ហាពីរលោកប្រធាន។ គឺថា តាមពិតគឺយើង<ហាក់ដូចជា>បានប្តឹងឧទ្ធរណ៍ប្រឆាំងទៅនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតមែន។ ដែលជាការពិតទៅ គឺ<ហាក់ដូចជាថា>យើងបានស្នើសុំ<ទៅ>អង្គជំនុំជម្រះនៅថ្ងៃទី១៨ ឧសភា ២០១១ គឺឯកសារ E88 ដើម្បីពិចារណាអំពីចំណុចនេះ។ នេះគឺចំណុចមួយ។ ចំណុចទី២ ខ្ញុំក៏ជឿជាក់ថាវាមានសារៈសំខាន់នោះផងដែរ។ ប៉ុន្តែខ្ញុំមិនបានលើកឡើងទេ រយៈពេលកន្លងមុននោះ ប៉ុន្តែវាពាក់ព័ន្ធទៅនឹងការពិភាក្សារបស់យើងនៅថ្ងៃនេះតែម្តង។ នៅក្នុងដីកាសម្រេចរបស់ក.ស.ច.ស ដោយបដិសេធសំណើសុំឱ្យតែងតាំងអ្នកជំនាញ គឺឯកសារ <D356/1> <ក.ស.ច.ស បានជំទាស់>នៅក្នុងកថាខណ្ឌ៧, ៨, ៩ និង១០ គឺនិយាយដូចតទៅ ខ្ញុំសូមដកស្រង់៖ “សហចៅក្រម -- តាមពិតទៅសហចៅក្រមស៊ើបអង្កេតបានពិចារណាទៅដល់លទ្ធភាពនៃការរៀបចំឱ្យមានគាស់រណ្តៅសាកសពមុននឹងសម្រេចជាថ្មីម្តងទៀត។ ហើយវាហាក់បីដូចជាប្រដូចថាការគាស់សពបែបធ្វើកោសល្យវិច័យនេះ គឺដើម្បីស្វែងរកភស្តុតាងបន្ថែម ដើម្បីសម្រាប់ការស្វែងរកការពិត ទោះបីជាភស្តុតាងនោះភស្តុតាងដោះបន្ទុក ឬក៏ដាក់បន្ទុកក្តី។” ហើយក្រោម កថាខណ្ឌក្រោមៗនិយាយអំពីប្រតិបត្តិការនៃការគាស់រណ្តៅសាកសព។ ប៉ុន្មាន<>ខែមកនេះ គឺថាយើងបានដឹងថាប្រតិបត្តិការគាស់រណ្តៅសាកសពនេះ គឺវាមានលក្ខណៈស្រដៀងគ្នាទៅនឹងការធ្វើកោសល្យវិច័យ។ គឺវា<បានធ្វើ>ទាំងនៅជើងឯកក៏ដូចជាមន្ទីរសន្តិសុខក្រាំងតាចាន់។ ដូច្នេះ នៅពេលនេះយើងកំពុងតែ<នៅ>ក្នុងដំណាក់កាលមួយដាក់សំណើសុំឱ្យតែងតាំងអ្នកជំនាញមួយរូបទៀត <ឬក៏>ថាតើ<បុគ្គលម្នាក់ដែលទទួលខុសត្រូវ>នៅជើងឯក <គួរតែត្រូវបានតែងតាំងជាអ្នកជំនាញ>ឬក៏យ៉ាងណានោះ។

<ជាការពិតណាស់ ការវិវឌ្ឍថ្មីមួយក្រោយពីមានសេចក្ដីសម្រេចរបស់ ក.ស.ច.ស និងការធ្វើកោសល្យវិច័យបានធ្វើឡើង ការ>គាស់រណ្ដៅសាកសព<>នៅទីតាំង<សំខាន់>ចំនួនពីរ<ត្រូវបានធ្វើឡើង>។ ដូច្នេះ យើងខ្ញុំយល់ឃើញថា នេះក៏ត្រូវតែយកមក -- អង្គជំនុំជម្រះក៏ត្រូវយកមកពិចារណាផងដែរ។ អង្គហេតុនេះ គឺថាវាជាធាតុមួយថ្មី ហើយសំខាន់ ដែលវាអាចនឹងជះឥទ្ធិពលទៅដល់សេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត។ ដូច្នេះយើងខ្ញុំស្នើសុំឲ្យអង្គជំនុំជម្រះមេត្តាពិចារណាទៅលើចំណុចនេះ លោកប្រធាន។ សូមអរគុណ។

[១០:៤៨:១៨]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំមិនដឹងច្បាស់ថា របាយការណ៍ទាំងពីរដែលលោកលើកឡើង<គឺពិតជា>ពាក់ព័ន្ធទៅនឹងការគាស់រណ្ដៅសាកសព<នោះទេ។ តាមការយល់របស់ខ្ញុំគឺថាមានការប្រមូល>លលាដ៍ក្បាល<រួចទៅហើយ។>

**លោក វ៉ិចទ័រ កូប៉េ៖**

<ពិតហើយ ខ្ញុំក៏យល់អ៊ីចឹងដែរ។ ប៉ុន្តែវាត្រូវបានគេរាប់ ហើយធាតុផ្សំមួយដែលគួរឲ្យចាប់អារម្មណ៍បំផុត>សម្រាប់មេធាវីការពារក្ដីនោះ គឺ<ថាតើ>ចំនួនលលាដ៍ក្បាល <និងឆ្អឹង>ដែលនៅសេសសល់ ដែលអាចរកឃើញ តើវាស៊ីសង្វាក់គ្នាទៅនឹងរបាយការណ៍ស្ដីអំពីការគាស់រណ្ដៅសាកសពដែលធ្វើឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជាដែរឬក៏អត់។ <ដូច្នេះ យើងមានឧទាហរណ៍ពីរគួរឲ្យចាប់អារម្មណ៍ខ្លាំងណាស់ ដែលមានសក្ដានុពល>ខុសគ្នា <រវាង>ការសិក្សាស្រាវជ្រាវដោយមជ្ឈ-មណ្ឌលឯកសារកម្ពុជាក្រោមការគ្រប់គ្រងរបស់ ក្រេក អេតឆេសាន់ នោះ<> និង<អ្វី>ដែល<ទើបបានរកឃើញដោយអ្នកដែល>ធ្វើការសិក្សាស្រាវជ្រាវថ្មីៗនេះឯង។ នេះគឺជាធាតុផ្សំមួយវាថ្មី ហើយសំខាន់ណាស់ដែលយើងខ្ញុំយល់ថា វាប៉ះពាល់ទៅដល់<ចំនួននៃ>ការស្លាប់<>ដោយអំពើហិង្សា ដែលសរសេរនៅក្នុងរបាយការណ៍នេះ។

[១០:៤៩:៣៩]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<ប៉ុន្តែជាថ្មីម្ដងទៀត ត្រឡប់ទៅរកភាពខុសគ្នារវាង វាគួរឲ្យចាប់អារម្មណ៍ និង>អ្វីដែល<គួរឲ្យ>ចាប់អារម្មណ៍ និងអ្វីដែលពាក់ព័ន្ធទៅនឹងបញ្ហាគតិយុត្ត។ <ជាការល្អបំផុត ប្រការនេះគួរតែ

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

អនុញ្ញាតឲ្យស្ទង់>មើលចំនួនអ្នកស្លាប់នៅក្នុងទីតាំងឧក្រិដ្ឋកម្ម<ជាក់លាក់ ឬក៏នៅទីតាំងឧក្រិដ្ឋកម្មជាក់លាក់ចំនួន>ពីរ<>។ <ប៉ុន្តែ>ថាតើវាពាក់ព័ន្ធទៅនឹងៗចំនួនអ្នកស្លាប់សរុបទាំងអស់ទូទាំងប្រទេសដោយរបៀបណា?

**លោក វ៉ិចទ័រ កូប៉េ៖**

ទាក់ទងទៅនឹងមន្ទីរសន្តិសុខស-២១ ខ្ញុំយល់សំណួររបស់លោកស្រីចៅក្រម។ ប្រហែលវាមិនពាក់ព័ន្ធនឹងបញ្ហាគតិយុត្តិនេះទេនៅស-២១ ប៉ុន្តែពាក់ព័ន្ធទៅនឹងនៅក្រាំងតាចាន់នោះ គឺវាពាក់ព័ន្ធទៅនឹងគោលនយោបាយជាក់លាក់ណាមួយដែលត្រូវបានអនុវត្ត។ ខ្ញុំយល់ឃើញថា មានចន្លោះប្រហោងខុសគ្នាច្រើនរវាងចំនួនអ្នកស្លាប់ដែលត្រូវបានប៉ាន់ប្រមាណ បើប្រៀបធៀបទៅនឹងចំនួនលលាដ៍ក្បាលដែលត្រូវបានរកឃើញនោះ។ <ចំណុចនេះអាចនិយាយបានអំពី>គោលនយោបាយដែលកំពុងតែ<ស៊ើបអង្កេតហើយ>--

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

លោកកំពុងតែយល់ច្រឡំហើយ។ <ខ្ញុំគិតថា លោកបានបង្កើតករណីមួយ ក្នុងចំណោមករណីជាច្រើនផ្សេងទៀត ហើយចំពោះ>អ្នកជំនាញ<ថ្មី>នេះ <លោកនិយាយថា> “គាត់ត្រូវតែពិនិត្យមើលទៅលើ<ការស្វែងរកអដ្ឋិធាតុ>ទាំង<អស់>នេះ <-- បញ្ហាទាំងអស់នេះ>។ ហើយអ្នកជំនាញនេះ គឺត្រូវនិយាយអំពី <>ចំនួនអ្នកស្លាប់សរុបទូទាំងប្រទេសតែម្តង។ តើ<ត្រូវបង្ហាញភស្តុតាងដោយរបៀបណា>?

[១០:៥១:១៦]

**លោក វ៉ិចទ័រ កូប៉េ៖**

<ពួកគេទាំងអស់ជា>អ្នកជំនាញខាងផ្នែកប្រជាសាស្ត្រ ហើយ<ពួកគេទាំងអស់ពឹងផ្អែកលើ>របាយការណ៍ស្តីអំពីការគាស់រណ្តៅសាកសពដោយមជ្ឈមណ្ឌលឯកសារកម្ពុជា។ <ពួកគេមិនបានចុះទៅដល់ទីតាំងរណ្តៅសពរួមណាមួយទេ ហើយក៏មិនបាន>ពិនិត្យមើល<>ថាតើការរកឃើញរបកគំហើញនៅក្នុងរបាយការណ៍នេះវាសុក្រឹត ឬក៏អត់។ <ឥឡូវនេះ> យើង<មាន>លទ្ធផល<ដ៏មានសក្តានុពល>នៃការគាស់រណ្តៅសាកសព<ចំនួនពីរ>ដែលធ្វើនៅពេលថ្មីៗ។ <> អ៊ីចឹងឯងបានថាវាសំខាន់ណាស់ដែលត្រូវឲ្យអ្នកជំនាញមកផ្តល់សក្ខីកម្ម។ <បើសិនជា>មានការខុសគ្នា<>រវាងរបកគំហើញ<នៃ>របាយការណ៍<ដែលគេបានយោងជាប្រភពនោះ ហើយនិងរបកគំហើញជាក់ស្តែង អ៊ីចឹង>វា

អាចនឹងបញ្ជាក់អំពីការកាត់បន្ថយ<នូវ>ចំនួន<អ្នក>សម្លាប់ដោយអំពើហិង្សាហ្នឹង គឺថាវាអាចនឹងមានចំនួនថយចុះឆ្ងាយពីនេះ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញព្រះរាជអាជ្ញា!

[១០:៥២:២១]

**លោក ឌេល លីសាក់៖**

មានចំណុចបីខ្លីៗទេ។ តាមពិតទៅការវិភាគរបស់អ្នកជំនាញ គឺថានៅតែអាចទទួលយកបាននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ទោះបីជាពួកគាត់មកទីនេះក្តី មិនមកចូលមកផ្តល់សក្ខីកម្មនៅទីនេះក្តី។ ហើយអ្នកដែលវិភាគពីបញ្ហានេះ ហើយរបាយការណ៍ដែលធ្វើឡើងដោយ 2-TCE-93 មានពន្យល់ពីចំណុចនេះ ហើយយើងមិនអាចនិយាយថា អង្គជំនុំជម្រះសាលាដំបូងរបស់យើងនេះមិនអាចពឹងផ្អែកទៅលើរបាយការណ៍របស់អ្នកជំនាញមួយបាននោះទេ មិនអាចថាយ៉ាងដូច្នេះបានទេ។ ទោះបីលោកសម្រេចទទួលយកចំនួនខ្ពស់បំផុត ឬចំនួនអ្នកស្លាប់ទាបបំផុតក្តី ក៏វា<បង្កើតឲ្យមានមូលដ្ឋានហួសពីសំណួរ>ថា <>មាន<ការរីករាលដាល និង>ការវាយប្រហារ<ជាប្រព័ន្ធ>លើជនស៊ីវិល។ <ចំណុចទី២> បញ្ហាដែលមាននៅចំពោះមុខយើងនៅថ្ងៃនេះ គឺថាតើ 2-TCE-93 នេះ អាចនឹងត្រូវកោះហៅហើយឲ្យគាត់<>ធ្វើបច្ចុប្បន្នភាព<ការវិភាគរបស់គាត់> ដោយ<ផ្អែកលើរបាយការណ៍ថ្មីដែលធ្វើដោយ ប៉ាទ្រីក អេវើលីន>។

[១០:៥៣:៥០]

ហើយជាក់ស្តែងទៅ ក៏វាអាច<>ធ្វើឲ្យកិច្ចដំណើរការនីតិវិធីនេះ<> មានដំណើរការទៅមុខជឿនលឿនបានផង <ក្នុងការពិនិត្យមើលភស្តុតាង>អ្នកជំនាញហ្នឹង <ជាជាងយកអ្នកជំនាញផ្សេងទៀតមកចំណាយពេលពីរបីខែដើម្បីសិក្សាការងាររបស់គាត់នោះ>។ អ៊ីចឹងបើលោកចង់<ស្តាប់សក្ខីកម្មរបស់អ្នកណាម្នាក់ អំពីបញ្ហា>ចំនួនអ្នកស្លាប់សរុបនោះ គឺថាការវិភាគថ្មី<របស់សាស្ត្រាចារ្យ អេវើលីន នេះ ពិតណាស់ជា>វិធីសាស្ត្រជឿនលឿនបំផុត <ដើម្បីពិចារណាលើភស្តុតាងថ្មីនេះ គួរតែកោះហៅគាត់ ជាជាង>ឲ្យអ្នកជំនាញ<ពីមុននោះ ចំណាយពេលរាប់ខែទៅ>ពិនិត្យមើលឯកសារ ឬក៏សំណេររបស់គាត់<>។ <ហើយចំណុចចុងក្រោយ ខ្ញុំប្រុងនឹងនិយាយបញ្ហាដូចគ្នានឹងលោកស្រី> ថៅក្រម ហ្វេនស៍ <បានលើកឡើងដែរ។> នេះមិនមែនជាការគាស់រណ្តៅសាកសពដែលធ្វើថ្មីៗទេ។

ការគាស់រណ្តៅសាកសពនេះ គឺធ្វើឡើងជាយូរយារណាស់មកមកហើយ ហើយហើយមិនមានលើកឡើងអំពីបញ្ហាដែលថា អ្នកស្លាប់នោះ គឺថាកើតដោយសារជម្លោះនៅ<ក្រោយ>ឆ្នាំ១៩៧៩ ឬក៏យ៉ាងណាទេ ពីព្រោះថា<នៅពេលដែលពលរដ្ឋត្រឡប់>ទៅក្រាំងតាចាន់ នៅជើងឯក <នៅពេលដែលពួកគេត្រូវបានអនុញ្ញាត>ឲ្យ<ត្រឡប់>ទៅផ្ទះវិញនោះ <ពួកគេបានរកឃើញរណ្តៅសាកសពទាំងអស់នេះ ដែលរណ្តៅទាំងអស់នេះ មិនបានកើតឡើងនៅពេលដែលពួកគេត្រូវបានបង្ខំឲ្យចាកចេញពីលំនៅដ្ឋានរបស់ពួកគេនៅឆ្នាំ១៩៧៥នោះ>ទេ។ ដូច្នេះមិនមានបញ្ហាពាក់ព័ន្ធទៅនឹងការស្លាប់ក្រោយឆ្នាំ១៩៧៩នោះទេ។ <ប៉ុន្តែចំណុចដែលមេធាវីការពារក្តីលើកឡើង គឺពិតជាចំណុចសំខាន់មួយមែន ព្រោះថា> ចំណុចភាពខុសគ្នារវាងអ្នកជំនាញ<ដែលតុលាការនេះកំពុងយកចិត្តទុកដាក់ ហើយនិង>អ្នកដែលធ្វើការសិក្សាស្រាវជ្រាវអំពីចំនួនលលាដ៏ក្បាលដែលត្រូវបានរកឃើញនៅជើងឯក <>គឺជាបញ្ហាមួយពាក់ព័ន្ធផ្ទាល់ទៅនឹងអង្គ -- សម្រាប់ការជំនុំជម្រះរបស់យើង ដែលពាក់ព័ន្ធទៅនឹងមន្ទីរសន្តិសុខស-២១។ អ្នកជំនាញនេះគឺថាគាត់ត្រូវទទួលការដឹង<>មានកម្រិតណាស់ <អំពីការគាស់រណ្តៅសាកសពនៅឆ្នាំ១៩៨០នោះ ដែលខ្ញុំជឿថា មាន>រណ្តៅសាកសពនៅជើងឯក<>ពីរភាគបី<>ត្រូវបានគេគាស់។ <នេះជាភស្តុតាងដែល>នៅសេសសល់ <ដែលយើងត្រូវធ្វើការ។> ហើយៗបុគ្គលដដែលនេះ <បានធ្វើការវិភាគមួយ>ពាក់ព័ន្ធទៅនឹងក្រាំងតាចាន់នោះ គឺវាមានលក្ខណៈខុសគ្នាទាំងស្រុងតែម្តង <ហើយពិតណាស់ គឺវាមានសារៈសំខាន់ មានភាពប្រញាប់បន្ទាន់ ហើយមានភាពសំខាន់ផ្ទាល់>ទៅនឹងបញ្ហាដែលយើងកំពុងពិភាក្សាគ្នានាពេលនេះតែម្តង។

**ប្រធានអង្គជំនុំ៖**

អរគុណលោកព្រះរាជអាជ្ញា។

ជាបន្តទៀត អង្គជំនុំជម្រះនឹងស្តាប់សារណាផ្ទាល់មាត់របស់នានា ពាក់ព័ន្ធនឹងសំណើតាមវិធាន ៨៧(៤)នៃវិធានផ្ទៃក្នុង សុំឲ្យទទួលយកឯកសារមួយចំនួនទាក់ទងនឹងអ្នកជំនាញ 2-TCE-82។

[១០:៥៧:០៧]

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំយល់ថាអង្គជំនុំជម្រះបានស្នើឲ្យភាគី <បញ្ជាក់>ថាតើខ្លួនត្រៀមខ្លួនឆ្លើយទៅនឹងសំណើយោងតាមវិធាន៨៧(៤) ដែលបានផ្ញើកាលពីម្សិលមិញល្ងាចឬក៏អត់ <ប៉ុន្តែយើងទើបតែបានទទួលនៅព្រឹកនេះទេ>។ មេធាវីការពារក្តីលោក ខៀវ សំផន សូមបញ្ជាក់ថា យើងខ្ញុំមិនទាន់ត្រៀមខ្លួន

ដើម្បីឆ្លើយតបទៅនឹងសំណើហ្នឹងទេ ពីព្រោះថា ព្រឹកនេះ ខ្ញុំនៅសវនាការ ហើយខ្ញុំអត់ដឹងរឿងសំណើហ្នឹងទេ។ ដូច្នេះខ្ញុំគិតថា អង្គជំនុំជម្រះគួរតែធ្វើ សវនាការនៅថ្ងៃចន្ទព្រឹកវិញលោកប្រធាន ហើយខ្ញុំដឹងថាអ្នកជំនាញនឹងមកនៅខាងមុខនេះ ពេលខាងមុខនេះហើយ ក៏ប៉ុន្តែខ្ញុំគិតថាទោះជាយ៉ាងណាក៏ដោយ ថ្ងៃចន្ទទើបអាចឲ្យភាគីផ្សេងៗហ្នឹង អាចធ្វើការកត់សម្គាល់សំខាន់ៗបានលោកប្រធាន។ អ៊ីចឹងឥឡូវនេះ ខ្ញុំអត់អាចត្រៀមលក្ខណៈអីឆ្លើយតបបានទេ លោកប្រធាន ខ្ញុំមិនទាន់បានពិនិត្យមើលឯកសារហ្នឹងឲ្យបានពេញលេញនៅឡើយទេ។

[១០:៥៨:១៣]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីការពារលោក នួន ជា!

**លោកស្រី ដូរីន ជិន៖**

ជម្រាបសួរសាជាថ្មីលោកប្រធាន។ គឺថាយើងមានជំហរដូចគ្នាទៅនឹងក្រុមមេធាវីការពារក្តីលោក ខៀវ សំផន។ <>យើង<ទើបតែ>បានទទួលឯកសារតាំងពីម្សិលមិញ ហើយយើងត្រៀមការចោទសួរសាក្សីរូបនេះ ដូច្នេះយើងខ្ញុំមិនមានជំហរអ្វីដែលអាចឆ្លើយបាននៅពេលនេះទេ។ យើងខ្ញុំសុំធ្វើការឆ្លើយតបនៅថ្ងៃចន្ទ។

*(ចៅក្រមពិភាក្សាគ្នា)*

[១០:៥៩:០៨]

**ប្រធានអង្គជំនុំ៖**

តើលោកព្រះរាជអាជ្ញា មានៗយោបល់យ៉ាងណាដែរចំពោះបញ្ហានេះ?

**លោក វីល្លៀម ស្មីត៖**

បាទ អរុណសួស្តីលោកប្រធាន លោក លោកស្រីចៅក្រម។ <>សហព្រះរាជអាជ្ញា <អាច> ឆ្លើយតបនៅថ្ងៃនេះ<បាន។> បើសិនណាជាក្រុមមេធាវីការពារក្តីស្នើសុំថានឹងឆ្លើយតបនៅថ្ងៃចន្ទ យើងគួរតែធ្វើយ៉ាងដូច្នេះទាំងអស់គ្នាតែម្តងទៅ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីដើមបណ្តឹងរដ្ឋប្បវេណី លោកមានយោបល់យ៉ាងណាដែរ?

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ យើងបានមើលឯកសារហ្នឹងកាលពីល្ងាចមិញហើយ។ អ៊ីចឹងយើងអាចឆ្លើយនៅពេលនេះក៏បាន រសៀលនេះក៏បាន ឬក៏ថ្ងៃចន្ទក៏បាន ទៅតាមការសម្រេចរបស់អង្គជំនុំជម្រះ។

[១១:០០:១៣]

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ ដល់ពេលសម្រាកអាហារថ្ងៃត្រង់ហើយ ខ្ញុំអង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ ហើយសវនាការបន្តធ្វើនៅថ្ងៃចន្ទ ទី០៥ ខែកញ្ញា ឆ្នាំ២០១៦ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។ សវនាការអំពីសំណើវិធាន៨៧(៤) និងសំណើរបស់អ្នកជំនាញ 2-TCE-93។

អង្គជំនុំជម្រះបង្គាប់ទៅមន្ទីរ -- អង្គជំនុំជម្រះបង្គាប់ទៅអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប លោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅថ្ងៃចន្ទ ទី០៥ ខែកញ្ញា ឆ្នាំ២០១៦ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សូមអញ្ជើញសម្រាក៕

*(សវនាការផ្អាកនៅម៉ោង ១១:០១ នាទី)*